# ព្រះរាជបញ្ញត្តិ
# អង្គការរៀបចំរលកអាកាសនិងគ្រប់គ្រងការប្រកបអាជីវកម្ម
# វិទ្យុសំលេង វិទ្យុទូរទស្សន៍ និងទូរគមនាគមន៍
# ព.ស.២៥៥៣

---

ភូមិផុល អះឌុលលះយះដេជ

ធ្វើនៅថ្ងៃទី ១៧ ធ្នូ ព.ស.២៥៥៣

ជាឆ្នាំទី ៦៥ ក្នុងសម័យរជ្ជកាលបច្ចុប្បន្ន

ព្រះបាទសម្តេចព្រះប៉រះមិន្ទ មហាភូមិផុលអះឌុលលះយះដេជ មានព្រះប្រមរាជឱង្ការអោយប្រកាសថា

ជាការគួរសមនៃការកែសម្រួលច្បាប់ស្តីពីអង្គការរៀបចំរលកអាកាសនិងគ្រប់គ្រងការប្រកបអាជីវកម្មវិទ្យុសំលេង វិទ្យុទូរទស្សន៍ និងទូរគមនាគមន៍

ព្រះរាជបញ្ញត្តិនេះមានបទបញ្ញត្តិប្រការខ្លះៗ ដែលកំណត់សិទ្ធិនិងសេរីភាពបុគ្គល ដែលមាត្រា ២៩ ប្រកបជាមួយមាត្រា ៣៥ មាត្រា ៣៦ មាត្រា ៤១ មាត្រា ៤៣ មាត្រា ៤៥ មាត្រា ៤៦ មាត្រា ៤៧ មាត្រា ៦១ និងមាត្រា ៦៤ របស់រដ្ឋធម្មនុញ្ញនៃរាជាណាចក្រថៃ បានចែងអោយប្រព្រឹត្តបាន ដោយអាស្រ័យអំណាចតាមបទបញ្ញត្តិនៃនិតិច្បាប់។

ទើបទ្រង់ព្រះករុណាអោយត្រាព្រះរាជបញ្ញត្តិតាមការណែនាំនិងឯកភាពពីរដ្ឋសភា ដូចតទៅ **មាត្រា ១** ព្រះរាជបញ្ញត្តិនេះហៅថា “ព្រះរាជបញ្ញត្តិអង្គការរៀបចំរលកអាកាសនិងគ្រប់គ្រងការប្រកបអាជីវកម្មវិទ្យុសំលេង វិទ្យុទូរទស្សន៍ និងទូរគមនាគមន៍ ព.ស.២៥៥៣”

**មាត្រា ២** ព្រះរាជបញ្ញត្តិនេះចូលជាធរមានចាប់តាំងពីថ្ងៃដែលប្រកាសក្នុងព្រះរាជក្រម

**មាត្រា ៣** អោយលុបចោលព្រះរាជបញ្ញត្តិអង្គការរៀបចំរលកអាកាសនិងគ្រប់គ្រងការប្រកបអាជីវកម្មវិទ្យុសំលេង វិទ្យុទូរទស្សន៍ និងទូរគមនាគមន៍ ព.ស.២៥៤៣

**មាត្រា ៤** ក្នុងព្រះរាជបញ្ញត្តិនេះ

“រលកអាកាស” មានន័យថា រលកវិទ្យុឬរលក hertz ដែលជា រលកអេឡិចត្រូម៉ាញ៉េទិក ដែលមានប្រេកង់ស៏តិចជាង ៣០០ លានមេហ្គាអែក្ស៍ ដែលត្រូវផ្សាយនៅតាមអវកាសដោយគ្មានអ្វីនាំ។ “ទូរគមនាគមន៍” មានន័យថា ការបញ្ជូន ការផ្សាយ ឬការទទួលសញ្ញា អក្សរ លេខ រូបភាព

សូរសំលេង លេខកូដ ឬអ្វីផ្សេងៗ ដែលអាចយល់ន័យដោយប្រព័ន្ធវិសាលគម ប្រព័ន្ធខ្សែ ប្រព័ន្ធពន្លឺ ប្រព័ន្ធអេឡិចត្រូម៉ាញ៉េទិក ឬប្រព័ន្ធផ្សេងៗ។

"វិទ្យុគមនាគមន៍" មានន័យថា ការបញ្ជូន ការផ្សាយ ឬការទទួលសញ្ញា អក្សរ លេខ រូបភាព សូរសំលេង លេខកូដ ឬអ្វីផ្សេងៗ ដែលអាចយល់ន័យដោយប្រព័ន្ធរលកអាកាស។

"វិទ្យុសំលេង" មានន័យថា វិទ្យុគមនាគមន៍ដែលបញ្ជូនឬផ្សាយសំលេងដើម្បីអោយបុគ្គលទូទៅបានទទួលផ្ទាល់។

"វិទ្យុទូរទស្សន៍" មានន័យថា វិទ្យុគមនាគមន៍ដែលផ្សាយរូបភាពឬសំលេងដើម្បីអោយបុគ្គលទូទៅទទួលផ្ទាល់។

"កិច្ចការផ្សាយសំលេង" មានន័យថា កិច្ចការវិទ្យុសំលេងនិងកិច្ចការផ្សាយសំលេងដែលបំរើសេវាបញ្ជូនសារពត៌មានសាធារណៈឬកម្មវិធីទៅម៉ាស៊ីនទទួលដែលអាចស្តាប់ការបំរើសេវានោះៗបាន។ ទាំងការបញ្ជូនតាមរយៈរលកអាកាស ប្រព័ន្ធខ្សែ ប្រព័ន្ធពន្លឺ ប្រព័ន្ធអេឡិចត្រូម៉ាញ៉េទិក ឬប្រព័ន្ធផ្សេងៗ ប្រព័ន្ធណាមួយ ឬច្រើនប្រព័ន្ធរួមគ្នា ឬកិច្ចការផ្សេងប្រហាក់ប្រហែលគ្នាតាមការកំណត់។

"កិច្ចការទូរទស្សន៍" មានន័យថា កិច្ចការវិទ្យុទូរទស្សន៍និងកិច្ចការទូរទស្សន៍ដែលបំរើសេវាបញ្ជូនសារពត៌មានសាធារណៈឬកម្មវិធីទៅម៉ាស៊ីនទទួលដែលអាចទស្សនានិងស្តាប់ការបំរើសេវានោះៗ បាន។ ទាំងការបញ្ជូនតាមរយៈរលកអាកាស ប្រព័ន្ធខ្សែ ប្រព័ន្ធពន្លឺ ប្រព័ន្ធអេឡិចត្រូម៉ាញ៉េទិក ឬប្រព័ន្ធផ្សេងៗ ប្រព័ន្ធណាមួយ ឬច្រើនប្រព័ន្ធរួមគ្នា ឬកិច្ចការផ្សេងប្រហាក់ប្រហែលគ្នាតាមការកំណត់។

"កិច្ចការវិទ្យុគមនាគមន៍" មានន័យថា កិច្ចការដែលជាការទទួលនិងបញ្ជូនសញ្ញា អក្សរ លេខ រូបភាព សូរសំលេង លេខកូដ ឬអ្វីផ្សេងៗ ដែលអាចបង្កអោយយល់សេចក្តីដោយប្រព័ន្ធរលកអាកាស។ ដោយមានគោលបំណងដើម្បីការទូរគមនាគមន៍ក្នុងកិច្ចការណាមួយឬជាការប្រើម្តងម្កាលដែលមិនមែនជាការប្រកបអាជីវកម្មកិច្ចការទូរគមនាគមន៍តាមច្បាប់ស្តីពីការប្រកបអាជីវកម្មកិច្ចការទូរគមនាគមន៍ ឬកិច្ចការផ្សាយសំលេងឬកិច្ចការទូរទស្សន៍។

"កិច្ចការទូរគមនាគមន៍" មានន័យថា កិច្ចការដែលបំរើសេវាបញ្ជូន ផ្សាយ ឬការទទួលសញ្ញា អក្សរ លេខ រូបភាព សូរសំលេង លេខកូដ ឬអ្វីផ្សេងៗ ដែលអាចធ្វើអោយយល់សេចក្តីដោយប្រព័ន្ធរលកអាកាស ប្រព័ន្ធខ្សែ ប្រព័ន្ធពន្លឺ ប្រព័ន្ធអេឡិចត្រូម៉ាញ៉េទិក ឬប្រព័ន្ធផ្សេងៗ ប្រព័ន្ធណាមួយ ឬច្រើនប្រព័ន្ធរួមគ្នា។ រួមទាំងកិច្ចការដែលបំរើសេវាផ្កាយរណបទំនាក់ទំនង ឬកិច្ចការនានាដែល

គណៈកម្មការកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ជាតិបានកំណត់ថាជាកិច្ចការទូរគមនាគមន៍។ ប៉ុន្តែមិនរួមកិច្ចការដែលជាកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការវិទ្យុគមនាគមន៍។

"តារាងកំណត់រលកអាកាស" មានន័យថា ការកំណត់រលកអាកាសរបស់វិទ្យុសំលេង វិទ្យុទូរទស្សន៍ វិទ្យុគមនាគមន៍ ទូរគមនាគមន៍ និងកិច្ចការផ្សេងៗ។ ដើម្បីប្រើប្រាស់តាមលក្ខណ្ឌដែល គណៈកម្មការកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ជាតិបានកំណត់។

"គម្រោងរលកអាកាស" មានន័យថា ការកំណត់ប៉ុស្តិ៍រលកអាកាសសម្រាប់កិច្ចការវិទ្យុសំលេង កិច្ចការវិទ្យុទូរទស្សន៍ កិច្ចការវិទ្យុគមនាគមន៍ និងកិច្ចការទូរគមនាគមន៍ ដើម្បីប្រើប្រាស់តាមលក្ខណ្ឌដែលគណៈកម្មការកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ជាតិបានកំណត់។

"ការរៀបចំរលកអាកាស" មានន័យថា ការអនុញ្ញាតិអោយស្ថានីយ៍វិទ្យុសំលេង ស្ថានីយ៍វិទ្យុទូរទស្សន៍ ឬស្ថានីយ៍វិទ្យុទូរគមនាគមន៍ ប្រើរលកវិទ្យុឬប៉ុស្តិ៍វិទ្យុតាមតារាងកំណត់រលកវិទ្យុឬគម្រោងរលកវិទ្យុ។ ដើម្បីប្រើប្រាស់តាមលក្ខណ្ឌដែលគណៈកម្មការកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ជាតិបានកំណត់។

"ទីប្រជុំជន" មានន័យថា ក្រុមប្រជាជនដែលស្នាក់អាស្រ័យនៅកន្លែងជាមួយគ្នា មិនថានៅក្នុងទីក្រុងឬក្នុងជនបទ។ មានន័យរួមទាំងក្រុមប្រជាជនដែលមានចំណាប់អារម្មណ៍ដូចគ្នានិងនៅកន្លែងជិតគ្នាឬអាចទាក់ទងគ្នាបាន។ ដោយមានផលប្រយោជន៍ផ្នែកសង្គមនិងវប្បធម៌ដែលមានទំនាក់ទំនងគ្នា ធ្វើសកម្មភាពដែលស្របច្បាប់និងស្របទៅតាមក្រមសីលធម្មជាមួយគ្នា មានការដំណើរការជាបន្តបន្ទាប់ មានការរៀបចំនិងបញ្ចេញមតិជំនួសក្រុមបាន។

"មូលនិធិ" មានន័យថា មូលនិធិស្រាវជ្រាវនិងអភិវឌ្ឍកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ ដើម្បីផលប្រយោជន៍ជាសាធារណៈ។

"កម្មការ" មានន័យថា កម្មការកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ជាតិ។

"មន្ត្រីសម្តកិច្ច" មានន័យថា អ្នកដែលគណៈកម្មការកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ជាតិ តែងតាំងអោយអនុវត្តតាមព្រះរាជបញ្ញត្តិនេះ។

**មាត្រា ៥** អោយនាយករដ្ឋមន្ត្រីជាអ្នកកាន់កាប់តាមព្រះរាជបញ្ញត្តិនេះ។

## ជំពូក ១

## គណៈកម្មការកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ជាតិ

---

### ផ្នែកទី ១

### សណ្ឋាន លក្ខណៈសម្បត្តិនិងលក្ខណៈដែលត្រូវហាមឃាត់របស់កម្មការ

---

**មាត្រា ៦** អោយមានគណៈកម្មការកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ជាតិ ហៅកាត់ថា “កសថឆ.” ចំនួនដប់មួយរូប រួមមាន

(១) អ្នកដែលមានស្នាដៃឬមានចំណេះដឹង និងអ្នកដែលមានជំនាញវិជ្ជាជីវៈឬមានបទពិសោធន៍ផ្នែកកិច្ចការផ្សាយសំលេង ចំនួនមួយរូប និងកិច្ចការទូរទស្សន៍ ចំនួនមួយរូប។

(២) អ្នកដែលមានស្នាដៃឬមានចំណេះដឹង និងអ្នកដែលមានជំនាញវិជ្ជាជីវៈឬមានបទពិសោធន៍ផ្នែកកិច្ចការទូរគមនាគមន៍ ចំនួនមួយរូប។

(៣) អ្នកដែលមានស្នាដៃឬមានចំណេះដឹង និងអ្នកដែលមានជំនាញវិជ្ជាជីវៈឬមានបទពិសោធន៍ផ្នែកច្បាប់ផ្នែកសេដ្ឋកិច្ច ដែលជាផលប្រយោជន៍ចំពោះការគ្រប់គ្រងកិច្ចការផ្សាយសំលេងកិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍មួយផ្នែកពីររូប។

(៤) អ្នកដែលមានស្នាដៃឬមានចំណេះដឹង និងអ្នកដែលមានជំនាញវិជ្ជាជីវៈឬមានបទពិសោធន៍ផ្នែកការការពារអ្នកបរិភោគ ឬផ្នែកជំរុញសិទ្ធិនិងសេរីភាពរបស់ប្រជាជន ដែលជាផលប្រយោជន៍ចំពោះការគ្រប់គ្រងកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍ ចំនួនមួយរូប និងការគ្រប់គ្រងកិច្ចការទូរគមនាគមន៍ ចំនួនមួយរូប។

(៥) អ្នកដែលមានស្នាដៃឬមានចំណេះដឹង និងអ្នកដែលមានជំនាញវិជ្ជាជីវៈឬមានបទពិសោធន៍ផ្នែកអប់រំ វប្បធម៌ឬការអភិវឌ្ឍសង្គម ដែលជាផលប្រយោជន៍ចំពោះការគ្រប់គ្រងកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ ចំនួនមួយរូប។

អោយលេខាធិការ កសថឆ. ជា លេខានុការ កសថឆ.

**មាត្រា ៧** កម្មការត្រូវមានលក្ខណៈសម្បត្តិនិងមិនមានលក្ខណៈត្រូវហាមឃាត់ដូចតទៅ

ក. លក្ខណៈសម្បត្តិទូទៅ

(១) មានសញ្ជាតិថៃចាប់ពីកំណើត

(២) មានអាយុមិនតិចជាង ៣៥ ឆ្នាំ ប៉ុន្តែមិនលើស ៧០ ឆ្នាំ

ខ. លក្ខណៈត្រូវហាមឃាត់

(១) កាន់មុខតំណែងនយោបាយ

(២) កាន់មុខតំណែងក្នុងបក្សនយោបាយ

(៣) ជាមនុស្សវិកលចរិតឬឆ្កួត

(៤) ញៀនថ្នាំ

(៥) ជាអ្នកក្ស័យធនឬជាអ្នកក្ស័យធនពុករលួយ

(៦) ជាប់ផ្តន់ទាទោសអោយជាប់ឃុំឃាំងឬត្រូវឃុំឃាំងដោយដីកាតុលាការ

(៧) ធ្លាប់ត្រូវកាត់ទោសថាប្រព្រឹត្តិបទល្មើសណាមួយ លើកលេងតែកំហុសដែលប្រព្រឹត្តិដោយធ្វេសប្រហែស កំហុសតិចតួច ឬកំហុសអំពីការមើលងាយ

(៨) ធ្លាប់ត្រូវបញ្ចេញចេញឬអោយចេញពីរាជការ អង្គភាពរបស់រដ្ឋឬសហគ្រាសរដ្ឋឬអង្គភាពឯកជន ដោយសារអំពើរពុករលួយឬប្រព្រឹត្តខុសធ្ងន់ធ្ងរ ឬចាត់ទុកថាជាការប្រព្រឹត្តអំពើរពុករលួយក្នុងរាជការ។

(៩) ធ្លាប់ត្រូវកាត់ទោសឬដីការបស់តុលាការអោយរិបយកទ្រព្យអោយជារបស់ប្លួងដោយសារតែមានខុសប្រក្រដីឬមានទ្រព្យកើនឡើងខុសប្រក្រដី។

(១០) មិនមែនជាតុលាការរដ្ឋធម្មនុញ្ញ គណៈកម្មការការបោះឆ្នោត អ្នកអភិបាលដែនដី កម្មការការពារនិងបង្ក្រាបអំពើរពុករលួយជាតិ កម្មការពិនិត្យហិរញ្ញវត្ថុជាតិ ឬកម្មការសិទ្ធិមនុស្សជាតិ

(១១) ធ្លាប់ត្រូវព្រឹត្តសភាមានមតិដកចេញពីតំណែង

(១២) មិនធ្លាប់ជាកម្មការឬជាកម្មការ អ្នកគ្រប់គ្រង នាយក ទីប្រឹក្សា បុគ្គលិក អ្នកកាន់ភាគហ៊ុន ឬមានភាគហ៊ុនរបស់ក្រុមហ៊ុនឬសាជីវកម្មនានាដែលប្រកបអាជីវកម្មកិច្ចការផ្នែកផ្សាយសំលេង កិច្ចការទូរទស្សន៍ ឬកិច្ចការទូរគមនាគមន៍ ក្នុងរយៈពេលមួយឆ្នាំមុនបានស្នើរឈ្មោះតាមមាត្រា ១០ ឬមុនត្រូវជ្រើសរើសតាមមាត្រា ១៥

(១៣) មិនស្ថិតនៅក្នុងអំឡុងពេលដែលត្រូវហាមឃាត់មិនអោយកាន់តំណែងផ្នែកនយោបាយ

**មាត្រា ៨** កម្មការត្រូវ

(១) មិនមែនជាមន្ត្រីរាជការដែលមានតំណែងឬមានប្រាក់ខែ

(២) មិនមែនជាភ្នាក់ងារឬនិយោជិករបស់អង្គភាពរដ្ឋ សហគ្រាសរដ្ឋឬមន្ត្រីរាជការក្នុងតំបន់ និងមិនមែនជាកម្មការឬទីប្រឹក្សារបស់សហគ្រាសរដ្ឋឬអង្គភាពរបស់រដ្ឋ។

(៣) មិនប្រកបអាជីវកម្មឬមានអាជីវកម្មសេរីនានាដែលអាចមានផលប្រយោជន៍ជំទាស់គ្នាជាមួយនឹងតំណែងកម្មការមិនថាតាមរយៈណាមួយឡើយ។

## ផ្នែកទី ២

## ការបានមកនូវឈ្មោះអ្នកដែលសមនឹងការត្រូវបានជ្រើសរើសជាកម្មការ ដោយការជ្រើសរើសគ្នាឯង

---

**មាត្រា ៩** ដើម្បីជាផលប្រយោជន៍សម្រាប់ការស្នើឈ្មោះអ្នកដែលសមនឹងការត្រូវបានជ្រើសរើសជាកម្មការតាមផ្នែកទី ៤ អោយសមាគម ស្ថាប័ន ឬអង្គភាពដែលមានលក្ខណៈដូចតទៅមានសិទ្ធិចុះបញ្ជីទុកចំពោះលេខាធិការព្រឹត្តិសភា។

(១) សហគមន៍វិជ្ជាជីវៈផ្នែកកិច្ចការផ្សាយសំលេងឬកិច្ចការទូរទស្សន៍ហើយបានចុះឈ្មោះជាសហគ្រាសមកហើយមិនតិចជាងប្រាំឆ្នាំ

(២) សហគមន៍វិជាជីវៈផ្នែកកិច្ចការទូរគមនាគមន៍ហើយបានចុះឈ្មោះជាសហគ្រាសមកហើយមិនតិចជាងប្រាំឆ្នាំ

(៣) ស្ថាប័នអប់រំដែលជាសហគ្រាសនិងមានការបង្រៀនថ្នាក់សញ្ញាប័ត្រផ្នែកការសំដែង វិជ្ជាជីវៈខាងសារពត៌មាន ឬអ្នកសារពត៌មាន រយៈពេលមិនតិចជាងប្រាំឆ្នាំ

(៤) ស្ថាប័នអប់រំដែលជាសហគ្រាសនិងមានការបង្រៀនថ្នាក់សញ្ញាប័ត្រ ផ្នែកទាក់ទងនិងទូរគមនាគមន៍ រយៈពេលមិនតិចជាងប្រាំឆ្នាំ

(៥) ស្ថាប័នអប់រំដែលជាសហគ្រាសនិងមានការបង្រៀនថ្នាក់សញ្ញាប័ត្រ ផ្នែកច្បាប់ រយៈពេលមិនតិចជាងប្រាំឆ្នាំ

(៦) ស្ថាប័នអប់រំដែលជាសហគ្រាសនិងមានការបង្រៀនថ្នាក់សញ្ញាប័ត្រ ផ្នែកសេដ្ឋកិច្ច រយៈពេលមិនតិចជាងប្រាំឆ្នាំ

(៧) អង្គការឯកជនដែលដំណើរការដោយមិនបានរកជំនេញឬចំណូលមកចែកគ្នា ដោយមានគោលបំណងដើម្បីការពារសិទ្ធិរបស់អ្នកបរិភោគ ឬការជំរុញសិទ្ធិនិងសេរីភាពរបស់ប្រជាជននិងបានចុះបញ្ជីជាសហាគ្រាសមកហើយមិនតិចជាងប្រាំឆ្នាំ។

(៨) ) អង្គការឯកជនដែលដំណើរការដោយមិនបានរកជំនេញឬចំណូលមកចែកគ្នា ដែលមានគោលបំណងដើម្បីការអប់រំ វប្បធម៌ និងការអភិវឌ្ឍសង្គម និងបានចុះបញ្ជីជាសហាគ្រាសមកហើយមិនតិចជាងប្រាំឆ្នាំ។

សមាគមវិជ្ជាជីវៈតាមកថាខណ្ឌទីមួយត្រូវជាសមាគមន៍ដែលមានគោលបំណងទាក់ទងនឹងវិជ្ជាជីវៈនិងមានសមាជិករបស់សមាគមជាអ្នកប្រកមវិជ្ជាជីវៈផ្នែកកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ឬកិច្ចការទូរគមនាគមន៍។

សមាគមឬអង្គការដែលមានសិទ្ធិស្នើសុំចុះបញ្ជីតាម (១) (២) (៧) និង (៨) ត្រូវជាសមាគមឬអង្គការដែលមានសកម្មភាពជាបន្តបន្ទាប់និងមានសមិទ្ធិផលច្បាស់លាស់។ ហើយបើសមាគមឬអង្គការណាដែលមានគោលបំណងច្រើនផ្នែក អោយជ្រើសចុះបញ្ជីជាសមាគមឬអង្គការតាម (១) (២) (៧) ឬ (៨) បានតែមួយប៉ុណ្ណោះ។

នៅពេលការិយាល័យលេខាធិការព្រឹត្តិសភាបានទទួលការចុះបញ្ជីសមាគម ស្ថាប័ន ឬអង្គការណាមួយតាមកថាខណ្ឌទីមួយហើយជាការស្រេច។ ការកាត់ក្តីរបស់តុលាការនៅពេលក្រោយថាការចុះបញ្ជីនោះមិនត្រឹមត្រូវ មិនអាចមានផលប៉ះពាល់ដល់ការដំណើរការដែលការិយាល័យលេខាធិការព្រឹត្តិសភាបានដំណើរការទៅមុនថ្ងៃដែលតុលាការបាន់កាត់ក្តី។

សមាគម ស្ថាប័ន ឬអង្គការនានាដែលត្រូវបដិសេធមិនអោយចុះបញ្ជីតាមកថាខណ្ឌទីមួយ។ អោយមានសិទ្ធិប្តឹងចំពោះតុលាការបាន ប៉ុន្តែការប្តឹងនោះមិនអាចផ្អាកឬបញ្ឈប់ការដំណើរការស្នើ ឈ្មោះឬជ្រើសរើសតាមព្រះរាជបញ្ញត្តិនេះ។

ការចុះបញ្ជីសមាគម ស្ថាប័ន និងអង្គការតាមកថាខណ្ឌទីមួយ អោយត្រូវទៅតាមគោលការណ៍ វិធីការនិងលក្ខណ្ឌដែលលេខាធិការព្រឹត្តិសភាបានប្រកាសកំណត់។

អោយការិយាល័យលេខាធិការព្រឹត្តិសភាប្រកាសឈ្មោះសមាគម ស្ថាប័ន ឬអង្គការដែលទទួលបានការចុះបញ្ជីអោយបានជ្រាបជាទូទៅ ហើយអោយបញ្ជីឈ្មោះនោះប្រើរហូតលុះដល់មានការកែសម្រួលតាមលក្ខណ្ឌដែលលេខាធិការព្រឹត្តិសភាបានប្រកាស់កំណត់។

**មាត្រា ១០** នៅពេលដែលត្រូវមានការជ្រើសរើសនិងតែងតាំងកម្មការ អោយការិយាល័យលេខាធិការព្រឹត្តិសភាប្រកាសតាមរយៈវិទ្យុសំលេង វិទ្យុទូរទស្សន៍ កាសេត និងសារពត៌មាន

អេឡិចត្រូនិកយ៉ាងតិចប្រាំពីរថ្ងៃជាប់គ្នា។ និងអោយសមាគម ស្ថាប័ន ឬអង្គការដែលបានចុះឈ្មោះតាមមាត្រា ៩ ដែលមានបំណងចង់ស្នើឈ្មោះអោយអ្នកដែលគួរបានជ្រើសរើសជាកម្មការ ស្នើឈ្មោះរួមទាំងលិខិតយល់ព្រមរបស់បុគ្គលនោះក្នុងរយៈពេលដែលលេខាធិការព្រឹទ្ធិសភាបានប្រកាសកំណត់ តាមលក្ខណ្ឌដូចតទៅ

(១) សមាគមវិជ្ជជីវៈតាមមាត្រា ៩ (១) និងស្ថាប័នអប់រំតាមមាត្រា ៩ (៣) មានសិទ្ធិស្នើឈ្មោះបុគ្គលតាមមាត្រា ៦ (១) បានមួយសមាគមពីររូប។

(២) សមាគមវិជ្ជជីវៈតាមមាត្រា ៩ (២) និងស្ថាប័នអប់រំតាមមាត្រា ៩ (៤) មានសិទ្ធិស្នើឈ្មោះបុគ្គលតាមមាត្រា ៦ (២) បានមួយសមាគមពីររូប។

(៣) ស្ថាប័នអប់រំតាមមាត្រា ៩ (៥) មានសិទ្ធិស្នើឈ្មោះបុគ្គលដែលមានស្នាដៃឬមានចំណេះដឹងនិងមានជំនាញវិជ្ជជីវៈឬបទពិសោធន៍ផ្នែកច្បាប់តាមមាត្រា ៦ (៣) បានមួយស្ថាប័នពីររូប។

(៤) ស្ថាប័នអប់រំតាមមាត្រា ៩ (៦) មានសិទ្ធិស្នើឈ្មោះបុគ្គលដែលមានស្នាដៃឬមានចំណេះដឹងនិងមានជំនាញវិជ្ជជីវៈឬបទពិសោធន៍ផ្នែកសេដ្ឋកិច្ចតាមមាត្រា ៦ (៣) បានមួយស្ថាប័នពីររូប។

(៥) អង្គការឯកជនតាមមាត្រា ៩ (៧) មានសិទ្ធិស្នើឈ្មោះតាមមាត្រា ៦ (៤) បានមួយអង្គការពីររូប។

(៦) អង្គការឯកជនតាមមាត្រា ៩ (៨) មានសិទ្ធិស្នើឈ្មោះតាមមាត្រា ៦ (៥) បានមួយអង្គការពីររូប។

ការដែលសមាគម ស្ថាប័ន ឬអង្គការដែលបានចុះបញ្ជីតាមមាត្រា ៩ សមាគម ស្ថាប័ន ឬអង្គការនានាដែលមិនស្នើឈ្មោះតាមកថាខណ្ឌទីមួយមិនថាដោយមូលហេតុណាក៏ដោយ មិនមែនជាមូលហេតុធ្វើអោយការជ្រើសរើសត្រូវផ្អាក។

**មាត្រា ១១** នៅពេលដែលគ្រប់កំណត់តាមមាត្រា ១០ ហើយ អោយការិយាល័យលេខាធិការព្រឹទ្ធិសភាពិនិត្យលក្ខណៈសម្បត្តិរបស់អ្នកដែលត្រូវគេស្នើឈ្មោះថាត្រឹមត្រូវតាមលក្ខណៈដែលបានកំណត់ក្នុងមាត្រា ៧ និងមាត្រា ១០ ឬទេ។ ក្នុងករណីដែលឃើញថាអ្នកដែលត្រូវគេស្នើឈ្មោះមានលក្ខណៈសម្បត្តិមិនត្រូវទៅតាមមាត្រា ៧ ឬមាត្រា ១០ អោយជូនពត៌មានប្រាប់សមាគម ស្ថាប័ន ឬអង្គការដែលស្នើឈ្មោះបុគ្គលនោះ ដំណើរការស្នើឈ្មោះជាថ្មីក្នុងរយៈពេលដែលលេខាធិការព្រឹទ្ធិសភាបានកំណត់។ នៅពេលដែលផុតកំណត់ហើយបើសមាគម ស្ថាប័ន ឬអង្គការនោះមិនស្នើឈ្មោះ អោយចាត់ទុកថាបានបដិសេធការស្នើឈ្មោះ។

នៅពេលដែលផុតកំណត់ការស្នើឈ្មោះតាមកថាខណ្ឌទីមួយឬតាមមាត្រា ១០ តាមតែករណី។ បើអ្នកដែលត្រូវគេស្នើឈ្មោះស្លាប់ ឬលុបចោលនៅលិខិតដែលយល់ព្រមអោយស្នើឈ្មោះ ឬខ្វះខាតលក្ខណៈសម្បត្តិមិនថាដោយ

ប្រការណាក៏ដោយ។ អោយការិយាល័យលេខាធិការព្រឹទ្ធិសភាដំណើរការជាបន្ត ដោយមិនចាំបាច់អោយមានការស្នើឈ្មោះថ្មីក៏បាន។

**មាត្រា ១២** នៅពេលដែលគ្រប់កំណត់ការស្នើឈ្មោះហើយ បើមានឈ្មោះអ្នកដែលត្រូវគេស្នើឈ្មោះច្រើនជាងពីរដងរបស់ចំនួនដែលបានបញ្ជាក់តាមប្រភេទនីមួយៗ តាមមាត្រា ១៣ (១) (២) (៣) (៤) និង (៥) អោយលេខាធិការព្រឹទ្ធិសភាពន្យារពេលការស្នើឈ្មោះទៅទៀតមិនលើសសាមសិបថ្ងៃចាប់ពីថ្ងៃដែលគ្រប់កំណត់តាមមាត្រា ១០។

នៅពេលដែលផុតកំណត់ពេលដែលបានពន្យារតាមកថាខណ្ឌទីមួយហើយនៅតែមានអ្នកដែលត្រូវគេស្នើឈ្មោះតិចជាងកំណត់តាមកថាខណ្ឌទីមួយ។ អោយនាយកដ្ឋានខុទ្ទកាល័យនាយករដ្ឋមន្ត្រី អគ្គនាយកដ្ឋានក្រសួងការពារជាតិ និងអគ្គនាយកដ្ឋានក្រសួងបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង រួមគ្នាស្នើឈ្មោះអ្នកដែលសមនឹងជ្រើសរើសជាកម្មការ។ ដែលមានលក្ខណៈសម្បត្តិនិងគ្មានលក្ខណ្ឌដែលត្រូវហាមឃាត់តាមមាត្រា ៦ និងមាត្រា ៧ អោយបានគ្រប់តាមចំនួនរបស់ប្រភេទនីមួយៗ តាមកថាខណ្ឌទីមួយ។

**មាត្រា ១៣** នៅពេលដែលផុតកំណត់ការស្នើឈ្មោះតាមមាត្រា ១០ មាត្រា ១១ ឬមាត្រា ១២ ក្នុងករណីណាមួយ។ អោយការិយាល័យលេខាធិការព្រឹទ្ធិសភារៀបចំអោយអ្នកដែលត្រូវគេស្នើរឈ្មោះទាំងអស់ប្រជុំរួមគ្នា ដើម្បីជ្រើសរើសគ្នាឯងតាមវិធីដូចតទៅ

(១) អ្នកដែលត្រូវគេស្នើឈ្មោះតាមមាត្រា ១០ (១) ពីសមាគមវិជ្ជាជីវៈតាមមាត្រា ៩ (១) ជ្រើសរើសគ្នាឯងអោយសល់អ្នកដែលគួរសមនឹងជាកម្មការតាមមាត្រា ៦ (១) ចំនួនពីររូប។ ដោយចែកជាផ្នែកកិច្ចការផ្សាយសំលេងចំនួនមួយរូប និងផ្នែកកិច្ចការទូរទស្សន៍ចំនួនមួយរូប និងអ្នកដែលត្រូវគេស្នើឈ្មោះតាមមាត្រា ១០ (១) ពីស្ថាប័នតាមមាត្រា ៩ (៣) ជ្រើសរើសគ្នាឯងអោយសល់អ្នកដែលគួរសមជាកម្មការតាមមាត្រា ៦ (១) ចំនួនពីររូប។ ដោយចែកជាផ្នែកកិច្ចការផ្សាយសំលេងចំនួនមួយរូប និងផ្នែកកិច្ចការទូរទស្សន៍ចំនួនមួយរូប។

(២) អ្នកដែលត្រូវគេស្នើឈ្មោះតាមមាត្រា ១០ (២) ពីសមាគមវិជ្ជាជីវៈតាមមាត្រា ៩ (២) ជ្រើសរើសគ្នាឯងអោយសល់អ្នកដែលគួរសមជាកម្មការតាមមាត្រា ៦ (២) ចំនួនពីររូប និងនិងអ្នកដែលត្រូវគេស្នើឈ្មោះតាមមាត្រា ១០ (២) ពីស្ថាប័នតាមមាត្រា ៩ (៤) ជ្រើសរើសគ្នាឯងអោយសល់អ្នកដែលគួរសមជាកម្មការតាមមាត្រា ៦ (២) ចំនួនពីររូប។

(៣) អ្នកដែលត្រូវគេស្នើឈ្មោះតាមមាត្រា ១០ (៣) និងមាត្រា ១០ (៤) អោយចែកគ្នាជ្រើសរើសគ្នាឯងអោយសល់អ្នកដែលគួរសមជាកម្មការតាមមាត្រា ៦ (៣) ចំនួនប្រាំបីរូប ដោយចែកជាផ្នែកច្បាប់ចំនួនបួនរូបនិងផ្នែកសេដ្ឋកិច្ចចំនួនបួនរូប។

(៤) អ្នកដែលត្រូវគេស្នើឈ្មោះតាមមាត្រា ១០ (៥) ជ្រើសរើសគ្នាឯងអោយសល់អ្នកដែលគួរសមជាកម្មការតាមមាត្រា ៦ (៤) ចំនួនបួនរូប។ ដោយចែកជាផ្នែកគ្រប់គ្រងកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍ចំនួនពីររូប និងផ្នែកគ្រប់គ្រងកិច្ចការទូរគមនាគមន៍ចំនួនពីររូប។

(៥) អ្នកដែលត្រូវគេស្នើឈ្មោះតាមមាត្រា ១០ (៦) ជ្រើសរើសគ្នាឯងអោយសល់អ្នកដែលគួរសមជាកម្មការតាមមាត្រា ៦ (៥) ចំនួនពីររូប។

ការបោះឆ្នោតជ្រើសរើសអោយត្រូវទៅតាមលក្ខណ្ឌនិងមធ្យោបាយដែលលេខាធិការព្រឹត្តិសភាបានកំណត់។ ដោយអោយអ្នកដែលបានពិន្ទុច្រើនបំផុតរៀងតាមលំដាប់ជាអ្នកដែលត្រូវបានជ្រើសរើស។

នៅពេលដែលបានជ្រើសរើសបុគ្គលតាមកថាខណ្ឌទីមួយនិងកថាខណ្ឌទីពីរហើយ។ អោយចាត់ទុកថាអ្នកដែលត្រូវបានគេជ្រើសរើសតាម (១) (២) (៣) (៤) និង (៥) ជាអ្នកដែលមានលក្ខណៈសម្បត្តិតាមមាត្រា ៦ (១) (២) (៣) (៤) និង (៥) ហើយការស្រេច។ ការដំណើរការជ្រើសរើសនោះត្រូវដំណើរការអោយរួចស្រេចក្នុងរយៈពេលមិនលើសពីកៅសិបថ្ងៃ ចាប់ពីថ្ងៃដែលបានប្រកាសអោយសមាគម ស្ថាប័ន ឬអង្គការដែលបានចុះបញ្ជីទុកបានស្នើឈ្មោះអ្នកដែលគួរសមនឹងត្រូវគេជ្រើសរើសជាកម្មការ។

ផ្នែកទី ៣

អំពីបញ្ជីឈ្មោះអ្នកដែលគួរសមត្រូវគេជ្រើសរើសជាកម្មការ

ដោយវិធីការជ្រើសរើស

---

**មាត្រា ១៤** នៅពេលដែលមានកិច្ចការដែលត្រូវជ្រើសរើសនិងតែងតាំងកម្មការ អោយមានកម្មការជ្រើសរើសមួយក្រុមចំនួនដប់ប្រាំនាក់ មានទួនាទីជ្រើសរើសអ្នកដែលគួរសមនឹងត្រូវគេជ្រើសរើសជាកម្មការ រួមមាន

(១) ប្រធានកម្មការសិទ្ធិមនុស្សជាតិ

(២) ប្រធានទីប្រឹក្សាសេដ្ឋកិច្ចនិងសង្គមជាតិ

(៣) នាយកដ្ឋានខុទ្ទកាល័យនាយករដ្ឋមន្ត្រី

(៤) នាយកដ្ឋានក្រសួងការពារជាតិ

(៥) នាយកដ្ឋានក្រសួងបច្ចេកវិជ្ជានិងការទំនាក់ទំនង

(៦) នាយកមជ្ឈមណ្ឌលអេឡិចត្រូនិចវិទ្យានិងកុំព្យូទ័រជាតិ

(៧) នាយកសភាវិស្វករ

(៨) ប្រធានសមាគមជនពិការគ្រប់ប្រភេទនៃប្រទេសថៃ

(១០) ប្រធានសមាគមវិជ្ជាជីវៈវិទ្យុសំលេងនិងវិទ្យុទូរទស្សន៍

(១១) ប្រធានគណៈកម្មការទំនាក់ទំនងអង្គការឯកជន

(១២) ប្រធានកម្មការសមាគមជំរុញស្ថាប័នកម្មការក្រុមហ៊ុនថៃ

(១៣) ប្រធានសភាវិជ្ជាជីវៈសារពត៌មានវិទ្យុនិងទូរទស្សន៍ថៃ

(១៤) ប្រធានសហព័ន្ធវិទ្យុសហគមន៍ជាតិ

(១៥) ប្រធានសហព័ន្ធអង្គការអ្នកបរិភោគ

ប្រធានកម្មការជ្រើសរើសមិនមានសិទ្ធិចុះឈ្មោះជាកម្មការ និងអង្គការតាមកថាខណ្ឌទីមួយមិនមានសិទ្ធិចុះបញ្ជីដើម្បីស្នើឈ្មោះអ្នកដែលគួរសមត្រូវគេជ្រើសរើសជាកម្មការតាមផ្នែកទី ២។

អោយគណៈកម្មការជ្រើសរើសដំណើរការជ្រើសរើសកម្មការមួយនាក់ ជាប្រធានកម្មការជ្រើសរើសនិងជ្រើសរើសកម្មការជ្រើសរើសទៀតមួយនាក់ ជាលេខានុការគណៈកម្មការជ្រើសរើស។

ក្នុងករណីដែលមិនមានកម្មការជ្រើសរើសក្នុងតំណែងណាមួយ ឬមានប៉ុន្តែមិនអាចបំពេញទូនាទីបាន។ បើកម្មការដែលនៅសល់នោះមានចំនួនមិនតិចជាងពាក់កណ្តាល អោយគណៈកម្មការជ្រើសរើសប្រកបរួមនឹងកម្មការជ្រើរើសដែលមាននៅសល់។

អោយការិយាល័យលេខាធិការព្រឹត្តិសភាមានទូនាទីជាអង្គភាពរដ្ឋបាលនៃការដំណើរការស្វែងរកនិងជ្រើសរើសកម្មការ។

**មាត្រា ១៥** ការដំណើរការជ្រើរើសកម្មការនេះ អោយការិយាល័យលេខាធិការព្រឹត្តិសភាប្រកាសជ្រើសរើសបុគ្គលដែលមានលក្ខណៈសម្បត្តិតាមមាត្រា ៦ អោយបានជ្រាបជាទូទៅតាមរយៈវិទ្យុសំលេង វិទ្យុទូរទស្សន៍ កាសេត និងសារពត៌មានអេឡិចត្រូនិចយ៉ាងតិចសាបសិបថ្ងៃជាប់គ្នា។

អ្នកដែលមានសិទ្ធិចុះឈ្មោះជាកម្មការត្រូវមិនមែនជាអ្នកដែលត្រូវគេស្នើឈ្មោះពីសមាគម ស្ថាប័នឬអង្គការតាមមាត្រា ១០

នៅពេលដែលផុតកំណត់តាមកថាខណ្ឌទីមួយហើយ អោយគណៈកម្មការជ្រើសរើសពិចារណាជ្រើសរើសអ្នកដែលចុះឈ្មោះដែលមានលក្ខណៈសម្បត្តិជាកម្មការអោយបានពីរដងនៃចំនួនរបស់កម្មការតាមមាត្រា ៦ (១) (២) (៣) (៤) និង (៥)

លក្ខណ្ឌនិងវិធីការជ្រើសរើសអោយត្រូវទៅតាមលេខាធិការព្រឹទ្ធិសភាបានកំណត់។ ដោយអោយអ្នកដែលមានពិន្ទុខ្ពស់បំផុតជាអ្នកឈ្នះ។

អោយនាំសេចក្តីក្នុងមាត្រា ១៣ កថាខណ្ឌទីបី មកអនុវត្តក្នុងការជ្រើសរើសអ្នកដែលគួរសមជាកម្មការនៃគណៈកម្មការជ្រើសរើសជាការអនុលោម។

អ្នកដែលត្រូវខូចខាតពីការជ្រើសរើស អាចប្តឹងតុលាការបាន ប៉ុន្តែមិនអាចផ្អាកឬបញ្ឈប់ការដំណើរការនានាដែលបានដំណើរការទៅហើយ។ លើកលេងតែតុលាការនឹងមានដីកាឬបទបញ្ជាផ្សេង។ បើតុលាការមានដីកាឬបទបញ្ជានានា ដែលបង្កអោយបុគ្គលដែលត្រូវបានជ្រើសរើសខ្វះខាតលក្ខណៈសម្បត្តិឬមានលក្ខណៈដែលត្រូវហាមឃាត់ឬត្រូវបានជ្រើសរើសដោយមិនស្របច្បាប់។ អោយអ្នកដែលត្រូវបានគេជ្រើសរើសនោះ ផុតពីតំណែងចាប់តាំងពីថ្ងៃដែលតុលាការបានមានដីកាឬបទបញ្ជា។

## ផ្នែកទី៤
## ការបោះឆ្នោតនិងការតែងតាំងកម្មការ

---

**មាត្រា ១៦** នៅពេលដែលបានរាយនាមអ្នកដែលគួរសមត្រូវគេជ្រើសរើសជាកម្មការពីការជ្រើសរើសក្នុងឯងតាមផ្នែកទី ២ និងពីការជ្រើសរើសតាមផ្នែកទី ៣ ហើយ។ អោយលេខាធិការព្រឹទ្ធិសភា នាំរាយនាមទាំងនោះទាំងអស់មករួមជាបញ្ជីមួយគ្នា។ បើមានអ្នកគួរសមនឹងត្រូវជ្រើសរើសជាកម្មការមិនតិចជាងពីរដងរបស់ចំនួនកម្មការតាមដែលបានចែងក្នុងមាត្រា ៦ (១) (២) (៣) (៤) និង (៥)។ អោយស្នើបញ្ជីរាយនាម រួមទាំងប្រវត្តិរូបនិងស្នាដៃរបស់បុគ្គលនោះ។ ហើយត្រូវបញ្ជាក់អោយច្បាស់ឬមានភ័ស្តុតាងបញ្ជាក់អោយច្បាស់ថាបុគ្គលនោះគួរសមតាមមាត្រា ៦ ចំពោះប្រធានព្រឹទ្ធិសភាក្នុងសាមសិបថ្ងៃចាប់ពីថ្ងៃដែលបាន

ទទួលរាយនាមតាមមាត្រា ១៣ និងមាត្រា ១៥ ដើម្បីស្នើអោយព្រឹត្តិសភាពិចារណានិងមានមតិជ្រើសរើសជាបន្ត។

ករណីដែលការដំណើរការដោយការជ្រើសរើសគ្នាឯងតាមផ្នែកទី ២ ឬវិធីការជ្រើសរើសតាមផ្នែកទី ៣ វិធីការណាមួយដំណើរការមិនទាន់រួចរាល់តាមកំណត់តាមមាត្រា ១៣ កថាខណ្ឌទីបី។ អោយលេខាធិការព្រឹត្តិសភានាំរាយនាមអ្នកដែលគួរសមត្រូវគេជ្រើសរើសជាកម្មការ។ ដោយវិធីការដែលដំណើរការរួចរាល់ហើយក្នុងកំណត់ពេល រួមទាំងប្រវត្តិរូបនិងស្នាដៃរបស់បុគ្គលនោះ។ ហើយត្រូវបញ្ជាក់អោយច្បាស់ឬមានភ័ស្តុតាងបញ្ជាក់អោយច្បាស់ថាបុគ្គលនោះគួរសមតាមមាត្រា ៦ ចំពោះប្រធានព្រឹត្តិសភាក្នុងសាមសិបថ្ងៃចាប់ពីថ្ងៃដែលបានទទួលរាយនាមតាមមាត្រា ១៣ និងមាត្រា ១៥ ដើម្បីស្នើអោយព្រឹត្តិសភាពិចារណានិងមានមតិជ្រើសរើសជាបន្ត។

**មាត្រា ១៧** អោយព្រឹត្តិសភាមានមតិជ្រើសរើសបុគ្គលពីបញ្ជីរាយនាមដែលលេខានុការព្រឹត្តិសភាស្នើអោយរួចរាល់ក្នុងហុកសិបថ្ងៃចាប់ពីថ្ងៃដែលបានទទួលបញ្ជីរាយនាម។ ដើម្បីអោយបានកម្មការ តាមមាត្រា ៦ ដោយអោយអ្នកដែលបានពិន្ទុច្រើនបំផុតជាអ្នកបានការជ្រើសរើស។ ដែលត្រូវធ្វើដោយការបោះឆ្នោតសម្ងាត់ ហើយជូនដំណឹងអោយអ្នកដែលបានគេជ្រើសរើសអោយបានជ្រាប។

នៅពេលដែលផុតកំណត់តាមកថាខណ្ឌទីមួយ បើនៅតែបានកម្មការមិនគ្រប់ចំនួនតាមមាត្រា ៦ អោយប្រធានព្រឹត្តិសភាជូនដំណឹងអោយនាយករដ្ឋមន្ត្រីបានជ្រាប។ ហើយអោយនាយករដ្ឋមន្ត្រីនាំបញ្ជីរាយនាមស្នើទៅគណៈរដ្ឋមន្ត្រីដើម្បីពិចារណានិងដំណើរការអោយបានកម្មការតាមមាត្រា ៦ អោយគ្រប់ចំនួន។ ដោយត្រូវដំណើរការអោយរួចរាល់ក្នុងសាមសិបថ្ងៃចាប់ពីថ្ងៃដែលនាយករដ្ឋមន្ត្រីបានជ្រាប។

អោយអ្នកដែលត្រូវគេជ្រើសរើសតាមកថាខណ្ឌទីមួយ ឬកថាខណ្ឌទីពីរ តាមតែករណី ប្រជុំរួមគ្នាក្នុងដប់ប្រាំថ្ងៃចាប់ពីថ្ងៃដែលមានអ្នកដែលត្រូវគេជ្រើសរើសជាកម្មការគ្រប់ចំនួន។ ដើម្បីជ្រើសរើសប្រធានកម្មការមួយរូបនិងអនុប្រធានកម្មការពីររូប។ ហើយជូនដំណឹងអោយនាយករដ្ឋមន្ត្រីបានជ្រាប។ និងអោយនាយករដ្ឋមន្ត្រីនាំទៅក្រាបបង្គំទូលស្តេចដើម្បីទ្រង់ព្រះករុណាតែងតាំងជាបន្ត។

**មាត្រា ១៨** ករណីអ្នកដែលត្រូវគេជ្រើសរើសតាមមាត្រា ១៧ មានលក្ខណៈហាមឃាត់តាមមាត្រា ៨ (១) (២) ឬ (៣) នាយករដ្ឋមន្ត្រីនឹងនាំសេចក្តីទៅក្រាបបង្គំគាល់ស្តេចដើម្បីទ្រង់ព្រះករុណាតែងតាំងបានលុះត្រាតែបុគ្គលនោះបានចុះចេញពីបុគ្គលតាមមាត្រា ៨ (១) ឬ (២) ឬបង្ហាញភស្តុតាង ដែលបញ្ជាក់ច្បាស់ថាខ្លួនបានបញ្ឈប់ការប្រកប

អាជីវកម្មតាមមាត្រា ៨ (៣) ជាស្ថាពរហើយ។ ដែលត្រូវប្រព្រឹត្តិក្នុងដប់ប្រាំថ្ងៃចាប់ពីថ្ងៃដែលបានត្រូវជ្រើសរើស។ ប៉ុន្តែបើបុគ្គលនោះមិនចុះចេញ ឬមិនបានបញ្ឈប់ការប្រកបអាជីវកម្មក្នុងពេលកំណត់។ ដោយចាត់ទុកថាបុគ្គលនោះមិនធ្លាប់បានការជ្រើសរើសជាកម្មការ។ ហើយអោយព្រឹត្តិសភាជ្រើសរើសកម្មការថ្មីពីបញ្ជីរាយនាមដែលលេខានុការព្រឹត្តិសភាបានស្នើតាមមាត្រា ១៦។

ផ្នែកទី ៥

អាណត្តិនៃការកាន់តំណែងនិងការចុះចេញពីតំណែងកម្មការ

---

**មាត្រា ១៩** កម្មការមានអាណត្តិក្នុងតំណែងប្រាំមួយឆ្នាំចាប់ពីថ្ងៃដែលព្រះមហាក្សត្រទ្រង់តែងតាំងនិងកាន់កាប់តំណែងបានមួយអាណត្តិប៉ុណ្ណោះ។

អោយកម្មការដែលចុះចេញពីតំណែងតាមអាណត្តិ កាន់តំណែងដើម្បីបំពេញទូនាទីជាបន្តលុះដល់ទ្រង់មានព្រះបរមរាជឧង្កាតែងតាំងកម្មការជាថ្មី។

មុនគ្រប់កំណត់តាមអាណត្តិមិនតិចជាងកៅសិបថ្ងៃ អោយការិយាល័យលេខានុការព្រឹត្តិសភា រៀបចំអោយមានការស្នើឈ្មោះនិងតែងតាំងកម្មការថ្មីអោយរួចរាល់ជាបន្ទាន់។

**មាត្រា ២០** ក្រៅពីការចុះចេញពីតំណែងតាមអាណត្តិហើយ កម្មការចុះចេញពីតំណែងនៅពេលដែល

(១) ស្លាប់

(២) មានអាយុគ្រប់ចិតសិបឆ្នាំ

(៣) សូមចុះចេញ

(៤) ខ្វះខាតលក្ខណៈសម្បត្តិឬមានលក្ខណៈត្រូវហាមឃាត់តាមមាត្រា ៧

(៥) ប្រព្រឹត្តិល្មើសតាមមាត្រា ៨

(៦) ព្រឹត្តិសភាមានមតិអោយចុះចេញពីតំណែងតាមមាត្រា ២១

(៧) ព្រឹត្តិសភាមានមតិអោយដកហូតចេញពីតំណែងតាមច្បាប់អមរដ្ឋធម្មនុញ្ញស្ដីពីការការពារនិងបង្ក្រាបអំពើពុករលួយ

ការចេញពីតំណែងកម្មការតាម (១) (២) ឬ (៣) អោយក្រាបបង្គំទូលដើម្បីជ្រាប។ បើជាការចេញពីតំណែងតាម (៤) (៥) (៦) ឬ (៧) អោយក្រាបបង្គំទូលដើម្បីមានបញ្ជាអោយចុះចេញពីតំណែង។ បទបញ្ជានោះអោយជា

ធរមានចាប់តាំងពីថ្ងៃដែលខ្វះខាតលក្ខណៈសម្បត្តិឬមានលក្ខណៈត្រូវហាមឃាត់ឬថ្ងៃដែលប្រព្រឹត្តិល្មើ ឬថ្ងៃដែលព្រឹត្តិសភាមានមតិអោយចុះចេញពីតំណែង ឬថ្ងៃដែលត្រូវដកចេញពីតំណែង តាមតែករណី។

ករណីតាមកថាខណ្ឌទីមួយ អោយកម្មការដែលនៅសល់បំពេញទូនាទីបន្តនិងចាត់ទុកថា កសថផ. ប្រកបទៅដោយកម្មការទ្រឹមដែលនៅសល់។ ប៉ុន្តែត្រូវមានចំនួនមិនតិចជាងប្រាំមួយនាក់។

ករណីដែលកម្មការចេញពីតំណែងមុនចប់អាណត្តិ អោយអ្នកដែលត្រូវតែងតាំងជំនួសកាន់កាប់តំណែងទ្រឹមអាណត្តិរបស់អ្នកដែលខ្លួមមកជំនួស។ ករីណីដែលអាណត្តិនៅសល់មិនដល់បីឆ្នាំ អោយអ្នកនោះមានសិទ្ធិទទួលការតែងតាំងបានមួយអាណត្តិទៀត។

ករណីប្រធានកម្មការឬអនុប្រធានកម្មការចុះចេញពីតំណែងតាមកថាខណ្ឌទីមួយ អោយ កសថផ. ប្រជុំដើម្បីជ្រើសរើសកម្មការមួយនាក់ជាប្រធានកម្មការឬអនុប្រធានកម្មការ។ ហើយជូនដំណឹងអោយនាយករដ្ឋមន្ត្រីបានជ្រាប។ នឹងអោយនាយករដ្ឋមន្ត្រីក្រាបបង្គំទូលដើម្បីទ្រង់មានបញ្ជាតែងតាំងជាប្រធានកម្មការឬអនុប្រធានកម្មការ តាមតែករណី។

**មាត្រា ២១** អោយតំណាងរាស្ត្រឬសមាជិកព្រឹត្តិសភាមិនតិចជាងមួយភាគបួនរបស់សមាជិកទាំងអស់ មានសិទ្ធិស្នើសុំចំពោះប្រធានព្រឹត្តិសភាដើម្បីអោយព្រឹត្តិសភាមានមតិអោយកម្មការចុះចេញពីតំណែង។ ព្រោះកម្មការនោះមានរឿងអាស្រូវឬមានកំហុសធ្ងន់ធ្ងរ។

មតិរបស់ព្រឹត្តិសភាតាមកថាខណ្ឌទីមួយត្រូវមានសំលេងមិនតិចជាងមួយភាគបីរបស់សមាជិកទាំងអស់ទ្រឹមដែលមាននៅ។

**មាត្រា ២២** បើប្រាកដថា កសថផ. មិនបំពេញទូនាទីតាមច្បាប់បានថែងយ៉ាងមានប្រសិទ្ធិភាព។ អោយបុគ្គលតទៅនេះមានសិទ្ធិស្នើសុំប្រធានព្រឹត្តិសភាដើម្បីអោយព្រឹត្តិសភាមានមតិអោយ កសថផ. ចុះចេញពីតំណែង។

(១) តំណាងរាស្ត្រចំនួនមិនតិចជាងមួយភាគបួននៃសមាជិកទាំងអស់របស់តំណាងរាស្ត្រទ្រឹមដែលមាននៅ។

(២) សមាជិកព្រឹត្តិសភាចំនួនមិនតិចជាងមួយភាគបួនរបស់សមាជិកព្រឹត្តិសភាទ្រឹមដែលមាននៅ។

(៣) ប្រជាជនដែលប្រើសេវា ដែលរងផលប៉ះពាល់ពីការប្រព្រឹត្តិតាមកថាខណ្ឌទីមួយចំនួនមិនតិចជាងពីរម៉ឺននាក់។ ដោយស្នើចំពោះប្រធានព្រឹត្តិសភាតាមលក្ខណ្ឌដែលប្រធានព្រឹត្តិសភាបានកំណត់។

មតិរបស់ព្រឹទ្ធិសភាតាមកថាខណ្ឌទីមួយត្រូវមានសំលេងមិនតិចជាងពីរភាគបីរបស់ចំនួនសមាជិកទាំងអស់ដែលមាននៅ។ ដោយការចុះមតិនោះត្រូវនាំរបាយការណ៍របស់គណៈកម្មការតាមដាននិងវាយតម្លៃការអនុវត្តជូនទៅព្រឹទ្ធិសភាតាមមាត្រា ៧២ មកពិចារណាជាមួយ។

ករណីដែលកម្មការចុះចេញពីតំណែងទាំងក្រុមតាមកថាខណ្ឌទីមួយ អោយគណៈកម្មការដែលចុះចេញពីតំណែងនោះនៅតែកាន់មុខតំណែងជាបន្ត។ រហូតដល់គណៈកម្មការក្រុមថ្មីបានមកបំពេញទួនាទីជំនួស។

## ផ្នែកទី ៦

## ការប្រជុំនិងសិទ្ធិអំណាចរបស់កម្មការ

---

**មាត្រា ២៣** ការប្រជុំ ការចុះមតិ និងការអនុវត្តការងាររបស់ កសថឆ. អោយស្របទៅតាមរបៀបដែល កសថឆ. បានកំណត់។

ក្នុងការប្រជុំ បើមានការពិចារណារឿងដែលកម្មការមួយណាមានផលប្រយោជន៍។ កម្មការរូបនោះគ្មានសិទ្ធិចូលប្រជុំ។

ការបំពេញទួនាទីរបស់ កសថឆ. អាចប្រគល់អោយកម្មការមួយរូបឬច្រើនរូបបំពេញទួនាទីជំនួស កសថឆ. បាន។ ប៉ុន្តែ កសថឆ. មិនអាចបដិសេធការទទួលខុសត្រូវបានឡើយ។

**មាត្រា ២៤** ការបំពេញទួនាទីរបស់ កសថឆ. ក្នុងរឿងណាដែលទាក់ទងឬមានផលប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ។ ត្រូវអនុវត្តតាមមតិអង្គប្រជុំ ហើយត្រូវប្រកាសរបាយការណ៍អង្គប្រជុំ រួមទាំងលទ្ធផលនៃការបញ្ចេញមតិទាំងរាយបុគ្គលនិងទាំងក្រុមអោយសាធារណៈបានជ្រាប តាមរយៈសារអេឡិចត្រូនិចរបស់ការិយាល័យ កសថឆ. និងដោយវិធីនានាដែលគួរសម។

ពត៌មានដែលប្រាកដក្នុងរបាយការណ៍ការប្រជុំ រឿងណាដែលមានពត៌មានទាក់ទងនិងរាជការមិនចាំបាច់ផ្សព្វផ្សាយក៏បាន។ កសថឆ. អាចមានមតិមិនអោយបង្ហាញពត៌មានចំពោះផ្នែកនោះក៏បាន។

ការបង្ហាញរបាយការណ៍ការប្រជុំរួមទាំងលទ្ធផលការបញ្ចេញមតិតាមកថាខណ្ឌទីមួយ ត្រូវដំណើរការក្នុងរយៈពេលមិនលើសពីសាមសិបថ្ងៃចាប់ពីថ្ងៃដែលមានការបញ្ចេញមតិ។ លើកលេងតែមានមូលហេតុចាំបាច់ត្រូវពន្យារពេលទៅទៀតមិនលើសដប់ប្រាំថ្ងៃ។ ប៉ុន្តែត្រូវបង្ហាញមូលហេតុដែលត្រូវពន្យារពេលជាមួយផង។

**មាត្រា ២៥** អោយកម្មការជាអ្នកកាន់កាប់តំណែងជាន់ខ្ពស់តាមច្បាប់អមរដ្ឋធម្មនុញ្ញស្ដីពីការការពារនិងបង្ក្រាបអំពើពុករលួយនិងជាមន្ត្រីសម្ដកិច្ចតាមច្បាប់ព្រហ្មទណ្ឌ។

**មាត្រា ២៦** អោយប្រធានកម្មការ អនុប្រធានកម្មការ និងកម្មការបំពេញទួនាទីពេញម៉ោង។

ប្រធានកម្មការ អនុប្រធានកម្មការ និងកម្មការ ទទួលប្រាក់ខែតាមដែលបានចែងក្នុងព្រះរាជក្រឹត្យ។

ប្រធានកម្មការ អនុប្រធានកម្មការ និងកម្មការ អាចបានទទួលប្រាក់បៀវត្តអំពីការធ្វើដំណើរទៅបំពេញបេសកកម្មក្រៅតំបន់មិនលើសពីអត្រាដែលបានចែងក្នុងព្រះរាជក្រឹត្យ ។

**មាត្រា ២៧** អោយ កសថឆ. មានសិទ្ធិអំណាចដូចតទៅ

(១) រៀបចំបង្កើតគម្រោងគ្រប់គ្រងរលកអាកាស តារាងកំណត់រលកអាកាសជាតិ គម្រោងគំរូកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍ គម្រោងគំរូកិច្ចការទូរគមនាគមន៍ គម្រោងរលកវិទ្យុ និងគម្រោងលេខទូរគមនាគមន៍។

(២) រៀបចំរលកអាកាសរវាងរលកអាកាសដែលប្រើសម្រាប់កិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ កិច្ចការវិទ្យុគមនាគមន៍ និងកិច្ចការទូរគមនាគមន៍។

(៣) កំណត់លក្ខណ្ឌ និងប្រភេទរបស់កិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍។

(៤) ពិចារណាអនុញ្ញាតនិងគ្រប់គ្រងការប្រើប្រាស់រលកអាកាសនិងម៉ាស៊ីនវិទ្យុគមនាគមន៍សម្រាប់ប្រកបអាជីវកម្មកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ ឬសម្រាប់កិច្ចការវិទ្យុគមនាគមន៍និងកំណត់លក្ខណ្ឌនិងវិធីការទាក់ទងនិងការអនុញ្ញាត ឬថ្លៃសេវានៃការអនុញ្ញាតនោះ។

(៥) កំណត់លក្ខណ្ឌការប្រើប្រាស់រលកអាកាសអោយប្រកបទៅដោយប្រសិទ្ធិភាពនិងគ្មានការរំខានគ្នា ទាំងកិច្ចការប្រភេទជាមួយគ្នានិងរវាងកិច្ចការប្រភេទនីមួយៗ។

(៦) ពិចារណាអនុញ្ញាតនិងគ្រប់គ្រងការប្រកបអាជីវកម្មកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ ដើម្បីអ្នកប្រើសេវាទទួលបានការបំរើសេវាដែលមានគុណភាព ប្រសិទ្ធិភាព ឆាប់រហ័ស ត្រឹមត្រូវ និងយុត្តិធម្ម។ ហើយកំណត់លក្ខណ្ឌនិងវិធីការទាក់ទងនិងការអនុញ្ញាត ឬថ្លៃសេវានៃការអនុញ្ញាតនោះ។

(៧) ពិចារណាអនុញ្ញាតនិងគ្រប់គ្រងការប្រើប្រាស់លេខទូរគមនាគមន៍ និងកំណត់លក្ខណ្ឌនិងវិធីការទាក់ទងនិងការអនុញ្ញាត ឬថ្លៃសេវានៃការអនុញ្ញាតនោះ។

(៨) កំណត់លក្ខណ្ឌនិងវិធីការប្រើប្រាស់ឬវិធីការផ្ជាប់សេវា។ និងលក្ខណ្ឌនិងវិធីការសម្រាប់កំណត់អត្រាតម្លៃនៃការប្រើប្រាស់ឬតម្លៃនៃការផ្ជាប់បណ្តាញកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍។ ទាំងកិច្ច

ការប្រភេទជាមួយគ្នានិងរវាងកិច្ចការប្រភេទនីមួយៗ អោយយុត្តិធម្មចំពោះអ្នកទទួលសេវា អ្នកបំរើសេវានិងអ្នកវិនិយោគ ឬរវាងអ្នកបំរើសេវាទូរគមនាគមន៍ ដោយយកប្រយោជន៍សាធារណៈជាគោល។

(៩) កំណត់រច្ចនាសម្ព័ន្ធអត្រាតម្លៃប្រើប្រាស់និងរច្ចនាសម្ព័ន្ធអត្រាបំរើសេវាកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ អោយយុត្តិធម្មចំពោះអ្នកប្រើសេវានិងអ្នកបំរើសេវា ដោយយកប្រយោជន៍សាធារណៈជាគោល។

(១០) កំណត់ស្តង់ដានិងលក្ខណៈបច្ចេកទេសដែលត្រូវការសម្រាប់ការប្រកបអាជីវកម្មកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ កិច្ចការទូរគមនាគមន៍ និងកិច្ចការវិទ្យុគមនាគមន៍។

(១១) រៀបចំយន្តការដើម្បីការពារមិនអោយមានការផ្តាច់មុខឬបង្កអោយការប្រកួតប្រជែងមិនមានភាពយុត្តិធម្មក្នុងកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍។

(១២) រៀបចំយន្តការអោយមានការពង្រីកសេវាផ្នែកទូរគមនាគមន៍អោយទូលាយនិងស្មើភាពតាមមាត្រា ៥០។

(១៣) ការពារសិទ្ធិនិងសេរីភាពរបស់ប្រជាជនពីការកេងប្រវ័ញ្ចរបស់អ្នកវិនិយោគនិងការពារសិទ្ធិភាពឯកជននិងសេរីភាពបុគ្គលសម្រាប់ការទំនាក់ទំនងគ្នាតាមរយៈទូរគមនាគមន៍និងជំរុញសិទ្ធិសេរីភាពនិងភាពស្មើភាពរបស់ប្រជាជននៃការប្រើប្រាស់និងការប្រើប្រយោជន៍ពីរលកអាកាសដែលប្រើសម្រាប់កិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍។

(១៤) ទំនាក់ទំនងទាក់ទងនឹងការគ្រប់គ្រងរលកអាកាសទាំងក្នុងប្រទេសនិងរវាងប្រទេស។

(១៥) ដោះស្រាយបញ្ហាទាក់ទងនឹងការរំខានគ្នារបស់រលកអាកាស។

(១៦) តាមដាននិងផ្តត់ការពិភាក្សាណែនាំការប្រកបអាជីវកម្មកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍និងកិច្ចការទូរគមនាគមន៍។

(១៧) រៀបចំលក្ខណ្ឌការបង្រួបបង្រួម ការកាន់កម្មសិទ្ធិឆ្លងប្រព័ន្ធ ឬការកាន់កាប់កិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍ដែលប្រើរលកអាកាស។ រវាងអ្នកសារពត៌មានគ្នាឯងឬបុគ្គលនានា ដែលអាចមានផលប៉ះពាល់ឬរារាំងដល់សេរីភាពក្នុងការទទួលពត៌មានឬបិទបាំងការទទួលពត៌មានរបស់ប្រជាជន។

(១៨) ជំរុញការរួមជាក្រុមរបស់អ្នកទទួលប័ណ្ណអនុញ្ញាត អ្នកផលិតកម្មវិធី និងអ្នកប្រកបវិជ្ជជីវៈសារពត៌មានដែលទាក់ទងនឹងកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍ ដើម្បីជាស្តង់ដាផ្នែកសីលធម៌សម្រាប់ការប្រកបអាជីវកម្មឬគ្រប់គ្រងការប្រកមអាជីវកម្មក្រោមស្តង់ដាសីលធម៌។

(១៩) រៀបចំបទដ្ឋានបឬប្រកាសតាមមាត្រា ៥៨

(២០) អនុម័តថវិកាចំណាយរបស់ការិយាល័យ កសថឆ. រួមទាំងថវិកាដែលនឹងរៀបចំសម្រាប់ចូលមូលនិធិតាមមាត្រា ៥២

(២១) ពិចារណានិងផ្តល់មតិទាក់ទងនឹងការរៀបចំប្រាក់មូលនិធិតាមដែលគណៈកម្មការគ្រប់គ្រងមូលនិធិបានស្នើសុំតាមមាត្រា ៥៥

(២២) ផ្តល់ពត៌មាននិងសហការសម្រាប់ការចរចាឬធ្វើការឯកភាពរវាងរដ្ឋបាលនៃរាជាណាចក្រថៃនិងរដ្ឋបាលប្រទេសផ្សេងឬអង្គការរវាងប្រទេស។ ទាក់ទងទៅនឹងការគ្រប់គ្រងរលកអាកាស កិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ កិច្ចការទូរគមនាគមន៍ ឬកិច្ចការនានាដែលទាក់ទង។

(២៣) មានអនុសាសន៍ចំពោះគណៈរដ្ឋមន្ត្រីដើម្បីអោយមានច្បាប់ឬកែសម្រួលឬលុបចោលច្បាប់ដែលទាក់ទងនឹងការរៀបចំរលកអាកាសនិងសកម្មភាពផ្សេងៗ ដែលទាក់ទងនឹងរលកអាកាស កិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍និងកិច្ចការទូរគមនាគមន៍។

(២៤) ចេញបទដ្ឋាន ប្រកាស ឬបទបញ្ជាដែលទាក់ទងនឹងសិទ្ធិអំណាចរបស់ កសថឆ.

(២៥) អនុវត្តសកម្មភាពផ្សេងៗ តាមដែលបានចេញក្នុងព្រះរាជក្រឹត្តិឬច្បាប់ផ្សេង

ការរៀបចំលក្ខណ្ឌ ការបង្រួម ការកាន់កាប់សិទ្ធិឆ្លងប្រព័ន្ធឬការគាបសង្កត់តាម (១៧) អោយ កសថឆ. ស្តាប់មតិពីប្រជាជននិងអ្នកដែលទាក់ទងប្រកបជាមួយ។

ការប្រើសិទ្ធិអំណាចតាមកថាខណ្ឌទីមួយ ត្រូវមិនជំទាស់នឹងច្បាប់ស្តីពីការប្រកបអាជីវកម្មកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍។ ច្បាប់ស្តីពីការប្រកបកិច្ចការទូរគមនាគមន៍ និងច្បាប់ស្តីពីវិទ្យុគមនាគមន៍

បទដ្ឋាន ប្រកាស ឬបទបញ្ជានានាដែលបានដាក់អោយអនុវត្តជាទូទៅ នៅពេលដែលបានប្រកាសក្នុងព្រះរាជក្រមហើយអោយចូលជាធរមាន។

**មាត្រា ២៨** អោយ កសថឆ. រៀបចំអោយមានការស្តាប់មតិពីអ្នកដែលមានផលប្រយោជន៍រួមនិងប្រជាជនទូទៅ។ ដើម្បីយកមតិទៅបំពេញមុនពេលចេញបទដ្ឋាន ប្រកាស ឬបទបញ្ជា ទាក់ទងនឹងការគ្រប់គ្រងការប្រកបអាជីវ

កម្មកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ដែលមានជាធរមាននិងទាក់ទងនឹងការប្រកួតប្រជែងក្នុងការប្រកបអាជីវកម្មឬមានផលប៉ះពាល់ចំពោះប្រជាជន។ ដោយត្រូវផ្តល់ពត៌មានទាក់ទងនឹងដំណើរដើមទង មូលហេតុ និងការចាំបាច់ និងសរុបសារៈសំខាន់ទាក់ទងនឹងរឿងដែលនឹងស្តាប់មតិ រួមទាំងបញ្ហាដែលត្រូវការស្តាប់មតិ។ រយៈពេលនៃការស្តាប់មតិត្រូវមិនតិចជាងសាមសិបថ្ងៃ លើកលេងតែមានករណីចាំបាច់បន្ទាន់ កសថផ. អាចកំណត់រយៈពេលសម្រាប់ការស្តាប់មតិអោយតិចជាងរយៈពេលដែលបានកំណត់ទុកបាន។

អោយការិយាល័យ កសថផ. រៀបចំរបាយការណ៍សរុបលទ្ធផលការស្តាប់មតិប្រកបទៅដោយមតិនិងលទ្ធផលការពិចារណារបស់ កសថផ. ចំពោះមតិនោះ។ រួមទាំងមូលហេតុនិងផែនការបន្ទាប់។ ហើយផ្សព្វផ្សាយរបាយការណ៍នោះទៅតាមប្រព័ន្ធពត៌មានវិជ្ជារបស់ការិយាល័យ កសថផ.។

**មាត្រា ២៩** ការកំណត់អត្រាតម្លៃប្រើប្រាស់ឬថ្លៃសម្រាប់ការផ្ជាប់សេវា ថ្លៃផ្សេងៗ ឬថ្លៃសេវាសម្រាប់ការប្រកបអាជីវកម្មកិច្ចការវិទ្យុសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍តាមព្រះរាជក្រមនេះ និងតាមច្បាប់ស្តីពីការប្រកបអាជីវកម្មកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍។ អោយ កសថផ. ពិចារណាអំពីផលប្រយោជន៍សាធារណៈនិងផលលំបាករបស់អ្នកបរិភោគអោយស្របទៅនឹងដើមទុនក្នុងការបំរើសេវា ចំណេញ និងការរៀបចំធនធានដ៏មានប្រសិទ្ធិភាពផងដែរ។

**មាត្រា ៣០** ការបំពេញទួមាទីរបស់ កសថផ. កសថ. កថ២. គណៈកម្មការផ្សេងៗ និងគណៈអនុកម្មការដែលបានតែងតាំងតាមព្រះរាជក្រមនេះ។ រួមទាំងលេខាធិការ កសថផ. និងបុគ្គលិករបស់ កសថផ. ទាក់ទងនឹងការពិចារណាពាក្យសំណើរបស់ប្រជាជនតាមច្បាប់ របៀប ប្រកាស ឬកិច្ចសន្យាដែល កសថផ. ឬការិយាល័យ កសថផ. ធ្វើជាមួយឯកជន។ បើច្បាប់ របៀប បទដ្ឋាន ឬកិច្ចសន្យានោះមិនបានកំណត់រយៈពេលសម្រាប់ការដំណើរការ។ អោយ កសថផ. កំណត់ពេលវេលាសម្រាប់ការដំណើរការអោយរួចរាល់ហើយប្រកាសអោយប្រជាជនបានជ្រាប។ រឿងណាដែលមិនបានកំណត់ពេលវេលា ត្រូវដំណើរការអោយរួចរាល់ក្នុងរយៈពេលដប់ប្រាំថ្ងៃចាប់ពីបានទទួល។

ករណី កសថផ. កសថ. កថ២. គណៈកម្មការផ្សេងៗ និងគណៈអនុកម្មការដែលបានតែងតាំងតាមព្រះរាជក្រមនេះ។ លេខាធិការ កសថផ. និងបុគ្គលិករបស់ កសថផ. បំពេញទួនាទីយឺតយាវជាងរយៈពេលដែលបានចែងក្នុងកថាខណ្ឌទីមួយដោយគ្មានមូលហេតុគួរសម។ បើបង្កអោយមានការខូចខាតចំពោះបុគ្គលណាមួយ។ អោយការិយាល័យ កសថផ. ទទួលខុសត្រូវសងការខូចខាតចំពោះបុគ្គលនោះ។ ហើយអោយទារប្រាក់សងនោះពី កសថផ. កសថ. កថ២. ឬ

បុគ្គលិករបស់ការិយាល័យ កសថឆ. អ្នកដែលបង្កមូលហេតុធ្វើអោយយឺតយាវនោះ តាមតែករណី។ បើការខូចខាតនោះ មកពីទង្វើឬការដែលចេតនាមិនធ្វើឬធ្វេសប្រហេសយ៉ាងធ្ងន់ធ្ងរ។

**មាត្រា ៣១** ដើម្បីប្រយោជន៍ក្នុងការការពារអ្នកបរិភោគមិនអោយត្រូវកេងប្រវ័ញ្ចពីអ្នកវិនិយោគកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍។ អោយ កសថឆ. មានទួនាទីពិនិត្យការដំណើរការរបស់អ្នកវិនិយោគកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ មិនអោយការដំណើរការណាមួយមានការកេងប្រវ័ញ្ចអ្នកបរិភោគ។ ទាំងនេះអោយ កសថឆ. តែងតាំងគណៈអនុកម្មការជាពីរក្រុម ប្រកបទៅដោយអ្នកដែលមានចំណេះដឹង មានជំនាញ និងមានបទពិសោធន៍ដែលជាប្រយោជន៍សម្រាប់ការបំពេញទួនាទីរបស់ កសថឆ. ក្នុងការការពារអ្នកបរិភោគផ្នែកកិច្ចការទូរគមនាគមន៍។ ដោយអោយមានសិទ្ធិអំណាចក្នុងការពិចារណានិងស្នើមតិទាក់ទងនឹងបញ្ហាការបណ្តឹងនិងបំពេញទួនាទីផ្សេង ទាំងនេះ តាមតែ កសថឆ. បានកំណត់។

ករណីដែលអ្នកប្រកបអាជីវកម្មកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ ឬកិច្ចការទូរគមនាគមន៍ មានសកម្មភាពមួយណាដែលអាចជាការកេងប្រវ័ញ្ចអ្នកបរិភោគ។ ដោយការប្រើបណ្តញ្ចឬផ្សព្វផ្សាយពាណិជ្ជកម្មលក្ខណៈជាការយកកម្រៃលើសពីធម្មតាឬបង្កភាពរំខាន មិនថាវិធីការណាមួយតាមលក្ខណ្ឌដែល កសថឆ. កំណត់ អោយ កសថឆ. មានសិទ្ធិអំណាចបញ្ឈប់ការដំណើរការនោះបាន។

**មាត្រា ៣២** ដើម្បីការពារសិទ្ធិសម្រាប់ភាពឯកជននិងសេរីភាពរបស់បុគ្គលក្នុងការទំនាក់ទំនងគ្នាតាមរយៈទូរគមនាគមន៍។ អោយ កសថឆ. មានអំណាចកំណត់យន្តការការពារសិទ្ធិអ្នកប្រើប្រាស់សេវាទូរគមនាគមន៍ទាក់ទងនឹងពត៌មានផ្ទាល់ខ្លួន ភាពឯកជន និងសេរីភាពក្នុងការទំនាក់ទំនងរកគ្នាតាមរយៈទូរគមនាគមន៍។

ករណីដែលមានការល្មើសដោយការលួចស្តាប់ ប្រើប្រយោជន៍ ឬបង្ហាញសារឬពត៌មានផ្សេងៗដែលមានការទំនាក់ទំនងតាមរយៈទូរគមនាគមន៍ដោយមិនស្របច្បាប់ អោយចាត់ទុកថា កសថឆ. ជាអ្នកខូចខាតតាមច្បាប់ព្រហ្មទណ្ឌ។

ករណីដែលអ្នកដែលទទួលបានប័ណ្ណអនុញ្ញាតប្រកបអាជីវកម្មកិច្ចការទូរគមនាគមន៍ជាអ្នកល្មើសតាមកថាខណ្ឌទីពីរឬដឹងថាមានការល្មើសតាមកថាខណ្ឌទីពីរ។ ប៉ុន្តែប្រងើយកណ្តើយឬមិនដំណើរការតាមច្បាប់ក្នុងពេលដែលគួរសម។ អោយ កសថឆ. មានអំណាចបញ្ចផ្អាក់ឬដកហូតប័ណ្ណអនុញ្ញាតប្រកបអាជីវកម្មកិច្ចការទូរគមនាគមន៍បាន។

**មាត្រា ៣៣** អោយ កសថឆ. មានអំណាចតែងតាំងគណៈអនុកម្មការ ក្រុមការងារ ឬផ្តល់អោយមន្ត្រីសម្តកិច្ចបំពេញទួនាទីតាមព្រះរាជក្រមនេះ ឬតាមដែលបានទទួលបេសកកម្ម។

អនុកម្មការ និងក្រុមការងារត្រូវគ្មានលក្ខណៈហាមឃាត់តាមមាត្រា ៧ ខ. (១) (២) (៣) (៤) (៥) (៦) (៧) (៨) (៩) (១០) និង (១១)

**មាត្រា ៣៤** ក្នុងការបំពេញទូនាទីតាមព្រះរាជក្រមនេះ អោយ កសថឆ. កសថ. កថខ. និងគណៈកម្មការតាមដាននិងវាយតម្លៃការបំពេញទូនាទីមានអំណាចបញ្ជាអង្គភាពរបស់រដ្ឋឬបុគ្គលនានាអោយពន្យល់អំពីការពិតនិងបញ្ជូនឯកសារភស្តុតាងដែលទាក់ទងដើម្បីប្រកបជាមួយការពិចារណា។

## ជំពូក ២

## ការគ្រប់គ្រងការប្រកបអាជីវកម្ម

### ផ្នែកទី ១

### គណៈកម្មការកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍

**មាត្រា ៣៥** អោយគណៈកម្មការកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍មួយក្រុម ហៅកាត់ថា "កសថ." ប្រកបទៅដោយ

(១) ប្រធានកម្មការ ដែល កសថឆ. តែងតាំងពីអនុប្រធាន កសថឆ.

(២) កម្មការ ដែល កសថឆ. តែងតាំងពីកម្មការ កសថឆ. ដែលមិនមានជាប្រធានឬអនុប្រធាន កសថឆ. ចំនួនបួនរូប ដែលត្រូវមានកម្មការតាមមាត្រា ៦ (៣) ចំនួនពីររូប និងកម្មការតាមមាត្រា ៦ (៤) ចំនួនមួយរូប។

កម្មការតាមកថាខណ្ឌទីមួយនឹងជា កថខ. ក្នុងខណៈពេលជាមួយគ្នាមិនបាន។

អោយលេខាធិការ កសថឆ. តែងតាំងមន្ត្រីសម្តកិច្ចរបស់ការិយាល័យ កសថឆ. ជាលេខានុការនិងជំនួយការលេខានុការតាមការចាំបាច់។

**មាត្រា ៣៦** អោយនាំសេចក្តីតាមមាត្រ ២៣ មកអនុវត្តនៃការប្រជុំរបស់ កសថ. ។ លើកលេងតែផ្នែកដែលទាក់ទងនឹងអង្គប្រជុំ ត្រូវមានកម្មការ កសថ. ចូលប្រជុំមិនតិចជា ៣ ក់កណ្តលនៃចំនួនកម្មការ កសថ. ទាំងអស់ ទើបចាត់ទុកថាជាអង្គប្រជុំ។

ករណីដែលកម្មការ កសថ. ចុះចេញពីតំណែងមុនអាណត្តិ បើមានកម្មការ កសថ. នៅមិនតិចជាងបីរូប អោយកម្មការ កសថ. ដែលនៅសល់បំពេញទូនាទីជាបន្ត។

**មាត្រា ៣៧** អោយ កសថ. មានសិទ្ធិអំណាចបំពេញទូនាទីនានាជំនួស កសថផ. តាមមាត្រា ២៧ (៤) (៦) (៨) (៩) (១០) (១១) (១៣) (១៦) និង (១៨) នៅផ្នែកដែលទាក់ទងនឹងកិច្ចការផ្សាយសំលេង និងកិច្ចការទូរទស្សន៍និងបំពេញទូនាទីតាមដែល កសថផ. បានប្រគល់។

ផ្នែកទី ២

គណៈកម្មការកិច្ចការទូរគមនាគមន៍

---

**មាត្រា ៣៨** អោយគណៈកម្មការកិច្ចការទូរគមនាគមន៍មួយក្រុម ហៅកាត់ថា "កថខ." ប្រកបទៅដោយ

(១) ប្រធានកម្មការ ដែល កសថផ. តែងតាំងពីអនុប្រធាន កសថផ.

(២) កម្មការ ដែល កសថផ. តែងតាំងពីកម្មការ កសថផ. ដែលមិនមែនជាប្រធានឬអនុប្រធាន កសថផ. ចំនួនបួនរូប ដែលត្រូវមានកម្មការតាមមាត្រា ៦ (៣) ចំនួនពីររូប និងកម្មការតាមមាត្រា ៦ (៤) ចំនួនមួយរូប

កម្មការតាមកថាខណ្ឌទីមួយនឹងជា កសថ. ខណៈពេលជាមួយគ្នាមិនបានឡើយ

អោយលេខាធិការ កសថផ. តែងតាំងមន្ត្រីសម្ពកិច្ចរបស់ការិយាល័យ កសថផ. ជាលេខានុការនិងជំនួយលេខានុការតាមភាពចាំបាច់។

**មាត្រា ៣៩** អោយនាំសេចក្តីតាមមាត្រា ៣៦ មកអនុវត្តនៃការប្រជុំនិងការបំពេញទូនាទីរបស់ កថខ. ជាការអនុលោម។

**មាត្រា ៤០** អោយ កថខ. មានសិទ្ធិអំណាចនៃការបំពេញទូនាទីជំនួស កសថផ. តាមមាត្រា ២៧(៤) (៦) (៧) (៨) (៩) (១០) (១១) (១២) (១៣) និង (១៦) នូវផ្នែកដែលទាក់ទងនឹងកិ្ចការទូរគមនាគមន៍និងកិច្ចការវិទ្យុគមនាគមន៍ និងបំពេញទូនាទីផ្សេងៗ តាមដែល កសថផ. បានប្រគល់។

ផ្នែកទី ៣

ការគ្រប់គ្រងកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍

---

**មាត្រា ៤១** អ្នកណាមានបំណងនឹងប្រើរលកអាកាសដើម្បីកិច្ចការផ្សាយសំលេងឬកិច្ចការទូរទស្សន៍ ត្រូវទទួលប័ណ្ណអនុញ្ញាតតាមព្រះរាជក្រមនេះ។

ការសុំប័ណ្ណអនុញ្ញាត និងការអនុញ្ញាត អោយត្រូវទៅតាមគោលការណ៍ វិធីការ និងលក្ខណ្ឌដែល កសថផ. បានប្រកាស។ លើកលេងតែជាការវិនិយោគអោយត្រូវទៅតាមដែលបានចែងក្នុងកថាខណ្ឌទីប្រាំមួយ។

អោយចាត់ទុកថាការស្នើសុំប័ណ្ណអនុញ្ញាតតាមកថាខណ្ឌទីមួយ ជាការស្នើសុំប្រកបអាជីវកម្មកិច្ចការផ្សាយសំលេងឬកិច្ចការទូរទស្សន៍តាមច្បាប់ស្តីពីការប្រកមអាជីវកម្មកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍។ នៅពេលដែល កសថផ. បានអនុញ្ញាតអោយប្រើប្រាស់រលកអាកាសហើយ
អោយចាត់ទុកថាជាការអនុញ្ញាតអោយប្រកបអាជីវកម្មកិច្ចការផ្សាយសំលេងឬកិច្ចការទូរទស្សន៍តាមច្បាប់ស្តីពីការប្រកមអាជីវកម្មកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍។ និងចាត់ទុកថាបានអនុញ្ញាតអោយមាននិងប្រើប្រាស់ម៉ាស៊ីនវិទ្យុគមននគមន៍និងបង្កើតស្ថានីយ៍វិទ្យុគមនាគមន៍តាមច្បាប់ស្តីពីវិទ្យុគមនាគមន៍។ ទាំងនេះចំពោះផ្នែកដែលទាក់ទងនឹងម៉ាស៊ីនវិទ្យុគមនាគមន៍ដែលបានបញ្ជាក់នៅក្នុងពាក្យស្នើសុំ។

ការអនុញ្ញាតអោយប្រើប្រាស់រលកអាកាសដើម្បីកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍ត្រូវគិតអំពីប្រយោជន៍របស់ប្រជាជនថ្នាក់ជាតិ ថ្នាក់ភូមិភាគ និងថ្នាក់តំបន់ ក្នុងផ្នែកអប់រំ វប្បធម៌ ស្ថិរភាពរបស់រដ្ឋ និងប្រយោជន៍ជាសាធារណៈផ្សេងៗ។ រួមទាំងសេរីភាពនៃការប្រកួតប្រជែងនិងត្រូវដំណើរការកិច្ចការនានាអោយមានការពង្រាយផលប្រយោជន៍ជាទូទៅ អោយសមនឹងជាធនធានជាតិដើម្បីប្រយោជន៍ជាសាធារណៈ។

ដើម្បីជាការជំរុញកម្មវិធីវិទ្យុនិងកម្មវិធីទូរទស្សន៍ដែលមានគំនិតលើកស្ទួយសង្គមឬជាកម្មវិធីសម្រាប់កុមារនិងយុវជន។ អោយ កសថផ. កំណត់លក្ខណ្ឌសម្រាប់ការអនុញ្ញាតអោយអ្នកដែលទទួលប័ណ្ណអនុញ្ញាតត្រូវរៀបចំពេលអោយកម្មវិធីនោះបានផ្សាយក្នុងពេលដែលគួរសមសម្រាប់គ្រប់ក្រុមគោលដៅ។

ករណីដែលការអនុញ្ញាតអោយប្រើប្រាស់រលកអាកាសដើម្បីកិច្ចការផ្សាយសំលេងឬកិច្ចការទូរទស្សន៍ដែលជាការប្រកបអាជីវកម្មតាមដែលបានចែកក្នុងច្បាប់ស្តីពីការប្រកបអាជីវកម្មកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍។ អោយប្រើវិធីការជ្រើសរើសដោយការដេញថ្លៃរលកអាកាស ទាំងថ្នាក់ជាតិ ថ្នាក់ភូមិភាគ និងថ្នាក់តំបន់។ ដោយអោយចែកគ្នាដេញថ្លៃតាមថ្នាក់ ទាំងនេះតាមគោលការណ៍ វិធីការ រយៈពេល និងលក្ខណ្ឌដែល កសថផ. បានប្រកាសកំណត់។

ការកំណត់លក្ខណៈសម្បត្តិរបស់អ្នកដែលមានសិទ្ធិចូលដេញថ្លៃរលកអាកាសតាមកថាខណ្ឌទីប្រាំមួយ។ អោយគិតអំពីប្រយោជន៍ក្នុងការបែងចែកធនធានរលកអាកាសអោយប្រកបទៅដោយប្រសិទ្ធិភាពនិងមានតម្លៃ។ ការពារការផ្តាច់មុខ ជំរុញការប្រកួតប្រជែងដោយសេរីភាព ការបំរើសេវាប្រកបដោយប្រសិទ្ធិភាព និងការការពារសិទ្ធិរបស់

អ្នកដែលស្នើសុំប័ណ្ណអនុញ្ញាតប្រកបអាជីវកម្មថ្នាក់ភូមិភាគនិងថ្នាក់តំបន់។

ការអនុញ្ញាតអោយប្រើប្រាស់រលកអាកាសដើម្បីកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍ដែលបង្កអោយមានឬអាចមានការរំខានឬជាន់គ្នារបស់រលកអាកាសដែលបានការអនុញ្ញាតនៅមុនហើយមិនអាចធ្វើបានឡើយ។

**មាត្រា ៤២** អោយ កសថឆ. មានអំណាចកំណត់អត្រាតម្លៃប័ណ្ណអនុញ្ញាតតាមមាត្រា ៤១ ដោយចែកជាតម្លៃប័ណ្ណអនុញ្ញាតអោយប្រើរលកអាកាស និងតម្លៃប័ណ្ណអនុញ្ញាតប្រកបអាជីវកម្មដែលត្រូវបង់នៅពេលដែលបានទទួលប័ណ្ណអនុញ្ញាតហើយត្រូវបង់ជារៀងរាល់ឆ្នាំក្នុងអត្រាដែលគួរសមនឹងប្រភេទរបស់ប័ណ្ណអនុញ្ញាតតាមច្បាប់ស្តីពីការប្រកបអាជីវកម្មកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍។ លើកលេងតែតម្លៃប័ណ្ណអនុញ្ញាតអោយប្រើរលកអាកាសដើម្បីវិប្រកមអាជីវកម្មអោយចាត់ទុកថាប្រាក់ដែលបានពីការដេញថ្លៃតាមមាត្រា ៤១ កថាខណ្ឌទីប្រាំមួយជាថ្លៃប័ណ្ណអនុញ្ញាតអោយប្រើរលកអាកាសដែលត្រូវបង់នៅពេលដែលបានទទួលប័ណ្ណអនុញ្ញាតនិងនាំចូលមូលនិធិតាមមាត្រា ៥២។

ថ្លៃប័ណ្ណអនុញ្ញាតតាមកថាខណ្ឌទីមួយដែលត្រូវបង់ជារៀងរាល់ឆ្នាំ អោយ កសថឆ. កំណត់ដោយគិតអំពីចំណាយក្នុងការគ្រប់គ្រងការប្រើប្រាស់រលកអាកាសនិងការគ្រប់គ្រងការប្រកបអាជីវកម្មប្រកបដោយប្រសិទ្ធិភាពក្នុងអត្រារួមទាំងអស់មិនលើសពីពីរភាគរយរបស់ចំណូលមុនការកាត់ប្រាក់ចំណាយរបស់អ្នកកាន់ប័ណ្ណអនុញ្ញាត ហើយបញ្ជូនទៅជាប្រាក់ចំណូលរបស់ការិយាល័យ កសថឆ.។

អង្គភាពដែលបានការលើកលេងអោយមិនត្រូវអនុវត្តតាមច្បាប់ស្តីពីការប្រកបអាជីវកម្មកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍មិនថាទាំងអស់ឬមួយចំណែក។ ត្រូវបង់ថ្លៃតាមកថាខណ្ឌទីមួយដែរ។ ប៉ុន្តែ កសថឆ. អាចចុះថ្លៃអោយតាមការគួរសមក៏បាន ដោយគិតអំពីគោលបំណងនៃសកម្មភាពរបស់អង្គភាពនោះ។

**មាត្រា ៤៣** ប័ណ្ណអនុញ្ញាតអោយប្រើរលកអាកាសដើម្បីកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍ជាសិទ្ធិផ្ទាល់ខ្លួនរបស់អ្នកកាន់ប័ណ្ណ មិនអាចផ្ទេរសិទ្ធិបានឡើយ។

អ្នកកាន់ប័ណ្ណអនុញ្ញាតអោយប្រើប្រាស់រលកអាកាសដើម្បីកិច្ចការផ្សាយសំលេងឬកិច្ចការទូរទស្សន៍ត្រូវប្រកបអាជីវកម្មដោយខ្លួនផ្ទាល់ មិនអាចប្រគល់ការគ្រប់គ្រងទាំងអស់ឬមួយផ្នែកឬឯកភាពអោយបុគ្គលផ្សេងមានអំណាចជំនួសមិនបានឡើយ។ ប៉ុន្តែការអោយបុគ្គលជួលពេលដំណើរកម្មវិធីខ្លះៗ អាចធ្វើបានតាមគោលការណ៍ វិធីការ និងលក្ខណ្ឌដែល កសថឆ. បានកំណត់។

**មាត្រា ៤៤** អ្នកកាន់ប័ណ្ណអនុញ្ញាតអោយប្រើរលកអាកាសដើម្បីកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍។ អ្នកណាមិនប្រកបអាជីវកម្មក្នុងរយះពេលដែល កសថឆ. កំណត់ឬយករលកអាកាសទៅប្រើប្រាស់ខុសគោលដៅ ឬមិនអនុវត្តតាមលក្ខណ្ឌនៃកាប្រកបអាជីវកម្មដែលប្រើរលកអាកាស ឬប្រព្រឹត្តិអំពើដែលមានលក្ខណៈត្រូវហាមឃាត់តាមមាត្រា ២៧ (១១) និង (១៧) ឬមិនអនុវត្តតាមមាត្រា ៤៣។ អោយ កសថឆ. ដំណើរការដើម្បីអោយមានការកែសម្រួលអោយត្រឹមត្រូវឬមានបទបញ្ជាអោយដកហូតប័ណ្ណអនុញ្ញាតនោះទាំងអស់ឬមួយផ្នែក។

ផ្នែកទី ៤

ការគ្រប់គ្រងកិច្ចការទូរគមនាគមន៍

**មាត្រា ៤៥** អ្នកណាមានបំណងនឹងប្រើប្រាស់រលកអាកាសដើម្បីកិច្ចការទូរគមនាគមន៍ត្រូវមានប័ណ្ណអនុញ្ញាតតាមព្រះរាជបញ្ញត្តិនេះ។ ដែលត្រូវដំណើរការដោយការដេញថ្លៃរលកអាកាសតាមគោលការណ៍ វិធីការ រយះពេលនិងលក្ខណ្ឌដែល កសថឆ. បានកំណត់។ ដោយយកសេចក្តីតាមមាត្រា ៤១ កថាខណ្ឌទីបួន និងកថាខណ្ឌទីប្រាំពីរមកអនុវត្តជាការអនុលោម។ ហើយប្រាក់ដែលបានពីការដេញថ្លៃនៅពេលដែលកាត់ប្រាក់ចំណាយហើយអោយទៅជាប្រាក់ចំណូលជាតិ។

អោយចាត់ទុកថាការស្នើសុំប័ណ្ណអនុញ្ញាតប្រើប្រាស់រលកអាកាសតាមកថាខណ្ឌទីមួយ ជាការស្នើសុំប្រកបអាជីវកម្មកិច្ចការទូរគមនាគមន៍តាមច្បាប់ស្តីពីកាប្រកបអាជីវកម្មកិច្ចការទូរគមនាគមន៍ដែរ។ ហើយនៅពេលដែល កសថឆ. អនុញ្ញាតអោយប្រើប្រាស់រលកអាកាសហើយអោយចាត់ទុកថាអនុញ្ញាតអោយប្រកបអាជីវកម្មកិច្ចការទូរគមនាគមន៍តាមច្បាប់ស្តីពីការប្រកបអាជីវកម្មកិច្ចការទូរគមនាគមន៍ និងចាត់ទុកថាបានទទួលការអនុញ្ញាតអោយមាននិងអោយប្រើម៉ាស៊ីនវិទ្យុគមនាគមន៍និងបង្កើតស្ថានីយ៍វិទ្យុគមនាគមន៍តាមច្បាប់ស្តីពីការវិទ្យុគមនាគមន៍ដែរ។ ទាំងនេះចំពោះផ្នែកដែលទាក់ទងនឹងម៉ាស៊ីនវិទ្យុគមនាគមន៍ដែលបានបញ្ជាក់ក្នុងពាក្យស្នើសុំការអនុញ្ញាត។

អោយ កសថឆ. មានអំណាចកំណត់អត្រាថ្លៃប័ណ្ណអនុញ្ញាតប្រកបអាជីវកម្មកិច្ចការតាមច្បាប់ស្តីពីការប្រកបអាជីវកម្មកិច្ចការទូរគមនាគមន៍និងថ្លៃដេលត្រូវបង់រៀងរាល់ឆ្នាំ។ ដោយគិតពីចំណាយក្នុងការគ្រប់គ្រងការប្រើរលកអាកាសនិងការគ្រប់គ្រងការប្រកបអាជីវកម្មកិច្ចការប្រកបដោយប្រសិទ្ធិភាពក្នុងអត្រារួមមិនលើសពីពីរភាគរយ មុនកាត់ប្រាក់ចំណាយរបស់អ្នកដែលកាន់ប័ណ្ណអនុញ្ញាតនិងបញ្ជូនថ្លៃនោះទៅជាចំណូលរបស់ការិយាល័យ កសថឆ.។

**មាត្រា ៤៦** ប័ណ្ណអនុញ្ញាតអោយប្រើរលកអាកាសដើម្បីកិច្ចការទូរគមនាគមន៍ជាសិទ្ធិផ្ទាល់ខ្លួនរបស់អ្នកដែលកាន់ប័ណ្ណអនុញ្ញាត មិនអាចផ្ទេរអោយអ្នកដទៃបានឡើយ។

អ្នកដែលកាន់ប័ណ្ណអនុញ្ញាតអោយប្រើរលកអាកាសដើម្បីកិច្ចការទូរគមនាគមន៍ ត្រូវប្រកបអាជីវកម្មដោយខ្លួនផ្ទាល់ មិនអាចផ្ទេរការគ្រប់គ្រងទាំងអស់ឬផ្នែកណាមួយឬយល់ព្រមអោយបុគ្គលផ្សេងមានអំណាចប្រកបអាជីវកម្មជំនួសបានឡើយ។

**មាត្រា ៤៧** អ្នកកាន់ប័ណ្ណអនុញ្ញាតអោយប្រើប្រាស់រលកអាកាសដើម្បីកិច្ចការទូរគមនាគមន៍ដែលមិនប្រកបអាជីវកម្មកិច្ចការប្រើប្រាស់រលកអាកាសក្នុងរយៈពេលដែល កសថផ. កំណត់ ឬយករលកអាកាសទៅប្រើខុសគោលដៅ ឬមិនអនុវត្តតាមលក្ខណ្ឌក្នុងការប្រកបអាជីវកម្មដែលប្រើប្រាស់រលកអាកាសឬប្រព្រឹត្តិអំពើដែលត្រូវហាមឃាត់តាមមាត្រា ២៧(១១) ឬមិនអនុវត្តតាមមាត្រា ៤៥។ អោយ កសថផ. ដំណើរការអោយមានការកែសម្រួលអោយត្រឹមត្រូវ ឬមាមបទបញ្ជ ដកហូតប័ណ្ណអនុញ្ញាតទាំងអស់ឬមួយជំណែក។

ជំពូក ៣

គោលការណ៍ការរៀបចំបង្កើតគម្រោង

---

**មាត្រា ៤៨** អោយមានគម្រោងការគ្រប់គ្រងរលកអាកាសដែលយ៉ាងហោចណាស់ត្រូវមានកម្មវិធី ដូចតទៅ

(១) ពត៏មានលំអិតទាក់ទងនឹងតារាងកំណត់រលកអាកាសទាំងអស់ដែលប្រទេសថៃអាចនាំមកប្រើប្រាស់បាន។

(២) ផែនការក្នុងការដំណើរការទាក់ទងនឹងរលកអាកាសរវាងប្រទេស

(៣) ពត៏មានលំអិតទាក់ទងនឹងរលកអាកាសដែលរៀបចំអោយប្រើប្រាស់ក្នុងកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍ កិច្ចការទូរគមនាគមន៍ និងកិច្ចការផ្សេងៗ

(៤) មធ្យោបាយក្នុងការជូនរលកអាកាស់វិញ ដើម្បីនាំទៅបែងចែកជាថ្មីឬកែសម្រួកការប្រើរលកអាកាស

គម្រោងគំរូការគ្រប់គ្រងរលកអាកាស នៅពេលដែលប្រកាសក្នុងព្រះរាជក្រមនេះហើយអោយអនុវត្តបាននិងអោយជាគោលការណ៍ឬលក្ខណ្ឌក្នុងការអនុញ្ញាតនិងការដំណើរការកិច្ចការទាំងអស់ទាក់ទងនឹងការប្រើប្រាស់រលកអាកាស។

អោយ កសថឆ. តាមដានវាយតម្លៃការដំណើរការតាមគម្រោងគំរូការគ្រប់គ្រងរលកអាកាសនិងត្រូវកែសម្រួលគម្រោងគំរូនោះ ដើម្បីប្រយោជន៍នៃការគ្រប់គ្រងរលកអាកាសអោយប្រកបទៅដោយប្រសិទ្ធិភាពនិងអោយស្របទៅនឹងការជឿនលឿននៃបច្ចេកវិទ្យា។

សម្រាប់ការរៀបចំបង្កើតគម្រោងគំរូការគ្រប់គ្រងរលកអាកាស អោយ កសថឆ. ស្តាប់មតិពីប្រជាជនអ្នកប្រកបអាជីវកម្មដែលជាអ្នកប្រើប្រាស់រលកអាកាស និងអង្គភាពរបស់រដ្ឋដែលទាក់ទង ដើម្បីជាពត៌មានបូករួមក្នុងការពិចារណា។ ដោយរយៈពេលសម្រាប់ការស្តាប់មតិត្រូវមិនតិចជាងសាមសិបថ្ងៃ និងត្រូវគិតអំពីការប្រើប្រាស់ផ្នែកសន្តិសុខរបស់រដ្ឋបាលតាមការគួរសម។

**មាត្រា ៤៩** ការគ្រប់គ្រងការប្រកបអាជីវកម្ម អោយ កសថឆ. រៀបចំអោយមានគម្រោងគំរូកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍ និងគម្រោងគំរូកិច្ចការទូរគមនាគមន៍ ដើម្បីជាគោលការណ៍ក្នុងការដំណើរការរយៈពេលប្រាំឆ្នាំ។ ដោយគម្រោងគំរូនោះត្រូវស្របទៅនឹងគម្រោងគំរូការគ្រប់គ្រងរលកអាកាស។ ហើយយ៉ាងហោចណាស់ត្រូវមានគោលការណ៍អភិវឌ្ឍន៍និងជំរុញការប្រកួតប្រជែងដោយសេរីរវាងអ្នកប្រកបអាជីវកម្ម។ គោលការណ៍ការអនុញ្ញាតអោយប្រើរលកអាកាសនិងការអនុញ្ញាតអោយប្រកបអាជីវកម្ម។ ដោយផ្នែកកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍ ត្រូវរៀបចំអោយប្រជាជនបានប្រើប្រាស់រលកអាកាសដើម្បីប្រយោជន៍សាធារណៈនិងមិនកេងប្រវ័ញ្ច។ ក្នុងការប្រកបអាជីវកម្មត្រូវមានកិច្ចការដែលបំរើសេវាប្រជាជនមិនលើសពីម្ភៃភាគរយសម្រាប់ការប្រកបអាជីវកម្មក្នុងតំបន់នីមួយៗ។

សម្រាប់ការរៀបចំគម្រោងគំរូតាមកថាខណ្ឌទីមួយ អោយ កសថឆ. ស្តាប់មតិពីប្រជាជន អ្នកប្រកបអាជីវកម្មនិងអង្គភាពរដ្ឋដែលទាក់ទង ដើម្បីជាគោលការណ៍សម្រាប់ការពិចារណា។ ដោយរយៈពេលសម្រាប់ការស្តាប់មតិត្រូវមិនតិចជាងសាមសិបថ្ងៃ។

ករណីដែល កសថឆ. ពិចារណារឿងណាមួយមិនស្របទៅនឹងគំនិតរបស់ប្រជាជន អ្នកប្រកបអាជីវកម្មឬអង្គភាពរដ្ឋតាមដែលមាននៅក្នុងការស្តាប់មតិតាមកថាខណ្ឌទីពីរ។ កសថឆ. ត្រូវពន្យល់និងបញ្ជាក់មូលហេតុអោយប្រជាជន អ្នកប្រកបអាជីវកម្ម ឬអង្គភាពរដ្ឋបានជ្រាប។

ប្រជាជន អ្នកប្រកបអាជីវកម្ម ឬអង្គភាពរដ្ឋតាមកថាខណ្ឌទីបី បើអ្នកណាយល់ឃើញថាគម្រោងគំរូដែល កសថឆ. រៀបចំជំទាស់នឹងរដ្ឋធម្មនុញ្ញរបស់រាជាណាចក្រថៃ អោយមានសិទ្ធិប្តឹងចំពោះតុលាការបាន ។

គម្រោងគំរូតាមកថាខណ្ឌទីមួយ នៅពេលដែលបានប្រកាសក្នុងព្រះរាជក្រមហើយ អោយផ្សាប់ជាមួយនិង កសថឆ. និងអង្គភាពរដ្ឋដែលទាក់ទង។

**មាត្រា ៥០** ដើម្បីប្រយោជន៍សម្រាប់ការរៀបចំអោយមានសេវាទូរគមនាគមន៍មូលដ្ឋានអោយគ្រប់ទីកន្លែងនិង សេវាដើម្បីសង្គមតាមច្បាប់ស្តីពីការប្រកបអាជីវកម្មកិច្ចការទូរគមនាគមន៍។ អោយ កសថឆ. រៀបចំផែនការអោយមានសេវាទូរគមនាគមន៍មូលដ្ឋានអោយគ្រប់ទីកន្លែងនិងសេវាដើម្បីសង្គម។ ដោយក្នុងផែនការត្រូវកំណត់តំបន់និងក្រុមគោលដៅ រយៈពេលសម្រាប់ការអនុវត្ត រួមទាំងការព្យាករប្រាក់ចំណាយដែលអាចមានក្នុងការអនុវត្តនោះ។

ការរៀបចំបង្កើតផែនការតាមកថាខណ្ឌទីមួយ អោយ កសថឆ. ពិពាក្សាជាមួយនឹងអង្គភាពរដ្ឋដែលទាក់ទង ដោយត្រូវស្របទៅនឹងនយោបាយរបស់រដ្ឋមន្ត្រីដែលបានប្រកាសចំពោះរដ្ឋសភា។

អោយ កសថឆ. ប្រកាសកំណត់ចំនួនប្រាក់ចំណាយដែលត្រូវទារពីអ្នកកាន់ប័ណ្ណអនុញ្ញាតប្រកបអាជីវកម្មកិច្ចការទូរគមនាគមន៍ដើម្បីយកទៅប្រើសម្រាប់ការគាំទ្រការរៀបចំអោយមានសេវាទូរគមនាគមន៍តាមកថាខណ្ឌទីមួយ។ ដោយត្រូវគិតអំពីចំណូលដែលអ្នកកាន់ប័ណ្ណអនុញ្ញាតទទួលបានពីការបំរើសេវាទូរគមនាគមន៍។

អោយ កសថឆ. ប្រកាសកំណត់ចំនួនប្រាក់ពីមូលនិធិតាមមាត្រា ៥៣ (៤) ដែលនឹងយកមកគាំទ្រអ្នកកាន់ប័ណ្ណអនុញ្ញាតដើម្បីអោយអាចមានលទ្ធភាពរៀបចំអោយមានការបំរើសេវានោះបាន។

**មាត្រា ៥១** ដើម្បីជំរុញអោយប្រជាជនបានប្រើប្រាស់រលកអាកាសតាមចំណែកដែលបានកំណត់ក្នុងមាត្រា ៤៩ កថាខណ្ឌទីមួយ។ អោយ កសថឆ. រៀបចំលក្ខណ្ឌ និងវិធីការក្នុងការជំរុញសហគមន៍អោយទៅជាអ្នកមានលក្ខណៈសម្បត្តិសម្រាប់ការស្នើសុំប័ណ្ណអនុញ្ញាតប្រកបអាជីវកម្មកិច្ចការផ្សាយសំលេងឬកិច្ចការទូរទស្សន៍ប្រភេទបំរើសេវាសហគមន៍ ការរកចំណូល និងការគាំទ្រអ្នកប្រកបអាជីវកម្មកិច្ចការបំរើសេវាសហគមន៍ដែលមានគុណភាព។ ដោយអោយទទួលមតិពីប្រជាជន និងអង្គភាពរបស់រដ្ឋដែលទាក់ទក ដែលរួមមាន

ចំណូលរបស់អ្នកប្រកបអាជីវកម្មកិច្ចការបំរើសេវាសង្គមត្រូវជាចំណូលដែលបានពីការបរិច្ចាក ការទ្រទ្រង់ស្ថានីយ៍ ឬចំណូលផ្សេងៗ ដែលមិនមានការផ្សព្វផ្សាយពាណិជ្ជកម្មឬប្រកបអាជីវកម្មកិច្ចការផ្សាយសំលេងឬកិច្ចការទូរទស្សន៍។

ការគាំទ្រអ្នកប្រកបអាជីវកម្មកិច្ចការបំរើសេវាសហគមន៍ដែលមានគុណភាពត្រូវជាការទ្រទ្រង់ការដំណើរការរបស់ស្ថានីយ៍ មិនមែនជាការគាំទ្រកម្មវិធីណាមួយ។ ហើយមានភាគរយមិនលើសពាក់កណ្ដាលរបស់ចំណូលទាំងអស់របស់អ្នកប្រកបអាជីវកម្មបំរើសេវាសហគមន៍ រួមទាំងត្រូវរៀបចំអោយមានការវាយតម្លៃការបំរើសេវានិងប្រសិទ្ធិភាពក្នុងការចំណាយប្រាក់ដែលបានពីការទ្រទ្រង់ ដើម្បីយកទៅរួមពិចារណាចែកចាយប្រាក់ទ្រទ្រង់ក្នុងលើកក្រោយ។

## ជំពូក ៤
## មូលនិធិស្រាវជ្រាវនិងអភិវឌ្ឍន៍កិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ ដើម្បីប្រយោជន៍សាធារណៈ

---

**មាត្រា ៥២** អោយរៀបចំបង្កើតមូលនិធិក្នុងការិយាល័យ កសថឆ. ហៅថា “មូលនិធិស្រាវជ្រាវនិងអភិវឌ្ឍន៍កិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ ដើម្បីប្រយោជន៍សាធារណៈ” ដោយមានគោលបំណងដូចតទៅ

(១) ដំណើរការអោយប្រជាជនបានទទួលសេវាផ្នែកកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍និងកិច្ចការទូរគមនាគមន៍គ្រប់ទីកន្លែង រួមទាំងជំរុញសហគមន៍និងគាំទ្រអ្នកប្រកបអាជីវកម្មកិច្ចការដែលបំរើសេវាសហគមន៍តាមមាត្រា ៥១

(២) ជំរុញនិងគាំទ្រការអភិវឌ្ឍន៍ធនធានទំនាក់ទំនង ការស្រាវជ្រាវនិងអភិវឌ្ឍន៍កិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ រួមទាំងលទ្ធភាពក្នុងការចេះដឹងអំពីបច្ចេកទេសផ្នែកការប្រើប្រាស់រលកអាកាស បច្ចេកវិទ្យា បច្ចេកទេសសម្រាប់ជួយសម្រួលអ្នកពិការ មនុស្សចាស់ ឬជួបការលំបាក រួមទាំងឧស្សាហកម្មទូរគមនាគមន៍និងឧស្សាហកម្មដែលទាក់ទង។

(៣) ជំរុញនិងគាំទ្រការអភិវឌ្ឍន៍បុគ្គលិកផ្នែកកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ កិច្ចការទូរគមនាគមន៍ និង ប ច្ចេ ក វិ ទ្យា រួ ម ទាំ ង កា រ ដំ ណើ រ កា រ រ ប ស់ អ ង្គ ភា ព ដែ ល មា ន ទួ នា ទី រៀ ប ចំ ស្ត ង់ ដា សីលធម៌ក្នុងការប្រកបអាជីវកម្មឬវិជ្ជាជីវៈតាមច្បាប់ស្តីពីការប្រកបអាជីវកម្មកិច្ចាករផ្សាយសំលេងនិងកិច្ចការទូរទស្សន៍។

(៤) គាំទ្រ ជំរុញ និងការពារអ្នកបរិភោគផ្នែកកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍។

(៥) គាំទ្រការដំណើរការតាមច្បាប់ស្តីពីមូលនិធិអភិវឌ្ឍសារពត៌មានមានសុវត្ថិភាពនិងផ្តួចផ្តើម ដោយរៀបចំប្រាក់អោយមូលនិធិ។

**មាត្រា ៥៣** មូលនិធិតាមមាត្រា ៥២ ប្រកបទៅដោយ

(១) ដើមទុនដំបូងដែលរដ្ឋបាលរៀបចំអោយ

(២) ប្រាក់ដែលបានពីការដេញថ្លៃរលកអាកាសតាមមាត្រា ៤១ កថាខណ្ឌទីប្រាំមួយ

(៣) ប្រាក់ដែលបានពីការរៀបចំតាមមាត្រា ៦៥ កថាខណ្ឌទីប្រាំមួយ

(៤) ប្រាក់ដែលបញ្ជូនចូលមូលនិធិតាមច្បាប់ស្តីពីការប្រកបអាជីវកម្មកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍ និងច្បាប់ស្តីពីការប្រកបអាជីវកម្មកិច្ចការទូរគមនាគមន៍

(៥) ប្រាក់ពិន័យដែលពិន័យតាមព្រះរាជបញ្ញត្តិនេះ និងតាមច្បាប់ស្តីពីការប្រកបអាជីវកម្មកិច្ចការផ្សាយសំលេង និងកិច្ចការទូរទស្សន៍និងច្បាប់ស្តីពីការប្រកបអាជីវកម្មការទូរគមនាគមន៍

(៦) ប្រាក់ឬទ្រព្យដែលគេប្រគល់អោយដើម្បីជាជំនួយមូលនិធិ

(៧) ប្រាក់ឬទ្រព្យដែលបានពីការផ្ទេរសិទ្ធិតាមមាត្រា ៩១

(៨) ផ្លែផ្កានិងចំណូលមូលនិធិ រួមទាំងប្រយោជន៍ប្រាក់កម្រៃពីការប្រើប្រាស់ ពីការស្រាវជ្រាវនិងអភិវឌ្ឍផ្នែកកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍

(៩) ប្រាក់និងទ្រព្យផ្សេងដែលត្រូវជារបស់មូលនិធិ

ប្រាក់មូលនិធិតាម (៤) និង (៧) អោយចំណាយបានចំពោះគោលបំណងតាមមាតត្រា ៥២ (១)

ប្រាក់មូលនិធិតាម (៤) ដែលទទួលបានពីកិច្ចការណាអោយចំណាយចំពោះកិច្ចការនោះប៉ុណ្ណោះ។ លើកលែងតែប្រាក់ដែលបានពីកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍ អោយចំណាយដើម្បីកិច្ចការផ្សាយសំលេងឬកិច្ចការទូរទស្សន៍ក៏បាន។

**មាត្រា ៥៤** អោយមានគណៈកម្មការគ្រប់គ្រងមូលនិធិមួយក្រុម ប្រកបដោយ

(១) ប្រធាន កសថឆ. ជាប្រធានកម្មការ

(២) នាយកដ្ឋាននាយករដ្ឋមន្ត្រី លេខាធិការគណៈកម្មការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិ នាយកដ្ឋានបញ្ជីកណ្តាល និងប្រធានមជ្ឈមណ្ឌលបច្ចេកទេសអេឡិចត្រូនិចនិងកុំព្យូទ័រជាតិជាកម្មការដោយតំណែង។

(៣) អ្នកមានវិជ្ជាជីវៈដែលមានចំណេះដឹងនិងបទពិសោធន៍ផ្នែកការអភិវឌ្ឍន៍បុគ្គលិកនិងវិជ្ជាជីវៈសារពត៌មានផ្សាយសំលេងចំនួនមួយនាក់ និងសារពត៌មានទូរទស្សន៍ចំនួនមួយនាក់ ដែលកម្មការតាម (១) និង (២) ជាអ្នកជ្រើសរើស។

(៤) អ្នកមានវិជ្ជាជីវៈដែលមានចំណេះដឹងនិងបទពិសោធន៍ផ្នែកការបំរើសេវាទូរគមនាគមន៍មូលដ្ឋានទូទៅឬក្នុងតំបន់ដាច់ស្រយ៉ាល។ រួមទាំងការបំរើសេវាផ្នែកទូរគមនាគមន៍ផ្តល់ជូនជនដែលលំបាក ដែលកម្មការតាម (១) និង (២) ជាអ្នកជ្រើសរើសចំនួនមួយរូប។

(៥) អ្នកមានវិជ្ជាជីវៈដែលមានចំណេះដឹងនិងបទពិសោធន៍ផ្នែកការពារសិទ្ធិអ្នកបរិភោគឬការជំរុញសិទ្ធិនិងសេរីភាពរបស់ប្រជាជន ដែលកម្មការតាម (១) និង (២) ជាអ្នកជ្រើសរើសចំនួនមួយរូប។

(៦) អ្នកមានវិជ្ជាជីវៈដែលមានចំណេះដឹងនិងបទពិសោធន៍ផ្នែកជំរុញនិងការពារសិទ្ធិរបស់ជនពិការនិងអ្នកជួបការលំបាក ដែលកម្មការតាម (១) និង (២) ជាអ្នកជ្រើសរើសចំនួនមួយរូប។

អោយលេខាធិការ កសថឆ. ជាកម្មការ និងលេខានុការ ហើយអោយលេខាធិការ កសថឆ. តែងតាំងភ្នាក់ងាររបស់ការិយាល័យ កសថឆ. ជាជំនួយលេខានុការ។

កម្មការតាមកថាខណ្ឌទីមួយ (៣) (៤) (៥) និង (៦) ត្រូវមិនមានលក្ខណៈហាមឃាត់តាមមាត្រា ៧ ខ. (១) (២) (៣) (៤) (៥) (៦) (៧) (៨) (៩) (១០) និង (១១) មានអាណត្តិក្នុងតំណែងមួយអាណត្តិបីឆ្នាំនិងអាចត្រូវតែងតាំងម្តងទៀតបាន ប៉ុន្តែមិនអាចកាន់តំណែងជាប់គ្នាលើសពីពីរអាណត្តិបានឡើយ។

អោយនាំមាត្រា ២៣ មកអនុវត្តក្នុងការប្រជុំរបស់គណៈកម្មការគ្រប់គ្រងមូលនិធិ

**មាត្រា ៥៥** គណៈកម្មការគ្រប់គ្រងមូលនិធិមានសិទ្ធិអំណាចក្នុងការគ្រប់គ្រងមូលនិធិនិងស្នើមតិទាក់ទងនឹងការរៀបចំប្រាក់មូលនិធិដើម្បីចំណាយតាមគោលបំណងតាមមាត្រា ៥២ ចំពោះ កសថឆ. ដើម្បីពិចារណាផ្តល់ការឯកភា

៣។ ករណីដែល កសថផ. មានមតិខុសពីគណៈកម្មការគ្រប់គ្រងមូលនិធិ កសថផ. ត្រូវផ្តល់ហេតុផលប្រកបជាមួយការពិចារណាផងដែរ។

អោយគណៈកម្មការគ្រប់គ្រងមូលនិធិបង្ហាញពត៌មានទាក់ទងនិងការរៀបចំប្រាក់មូលនិធិ និងការអនុវត្តតាមកថាខណ្ឌមួយអោយប្រជាជនបានជ្រាបតាមរយៈសារពត៌មានរបស់ការិយាល័យ កសថផ. ដោយត្រូវបង្ហាញពត៌មានអ្នកដែលស្នើសុំនិងអ្នកដែលទទួលបានប្រាក់ពីមូលនិធិនិងចំនួនប្រាក់ដែលទទួលបានទាំងអស់។

ការអភិរក្ស ការចំណាយ ការរៀបចំបញ្ជីនិងប្រព័ន្ធបញ្ជី អោយត្រូវទៅតាមរបៀបដែលគណៈកម្មការគ្រប់គ្រងមូលនិធិបានកំណត់។

## ជំពូក ៥
## ការិយាល័យគណៈកម្មការកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ជាតិ

---

**មាត្រា ៥៦** អោយមានការិយាល័យគណៈកម្មការកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ជាតិ ហៅកាត់ថា “ការិយាល័យ កសថផ.” ជាសាជីវកម្ម មានឋានៈជាអង្គភាពរបស់រដ្ឋដែលមិនមែនផ្នែកមន្ត្រីរាជការតាមច្បាប់ស្តីពីរបៀបគ្រប់គ្រងដែនដីនិងមិនមែនជាសហគ្រាសរដ្ឋតាមច្បាប់ស្តីពីវិធីការថវិកាឬច្បាប់ផ្សេង ហើយនៅក្រោមការគ្រប់គ្រងរបស់ប្រធានកម្មការ។

កិច្ចការរបស់ការិយាល័យ កសថផ. មិននៅក្រោមការបង្គាប់របស់ច្បាប់ស្តីពីការគ្រប់គ្រងពលករ ច្បាប់ស្តីពីពលករសម្ព័ន្ធ ច្បាប់ស្តីពីការធានារ៉ាប់រងសង្គមនិងច្បាប់ស្តីពីប្រាក់សំណង។

**មាត្រា ៥៧** អោយការិយាល័យ កសថផ. មានសិទ្ធិអំណាចដូចតទៅ

(១) ទទួលខុសត្រូវក្នុងការទទួលនិងចំណាយប្រាក់ចំណូលរបស់ការិយាល័យ កសថផ.

(២) រៀបចំថវិកាប្រាក់ចំណាយប្រចាំឆ្នាំរបស់ការិយាល័យ កសថផ. ដើម្បីស្នើអោយ កសថផ. អនុម័ត។ ដោយប្រាក់ចំណាយប្រចាំឆ្នាំរបស់ការិយាល័យ កសថផ. មានន័យរួមទាំងប្រាក់ចំណាយនានា ដែលទាក់ទងនឹងការអនុវត្តតាមអំណាចរបស់ កសថផ. កសថ. កថខ. និងការិយាល័យ កសថផ.។

(៣) ពិនិត្យនិងតាមដានការប្រើប្រាស់រលកអាកាស

(៤) ទទួលនិងពិចារណាក្តីបណ្តឹងទាក់ទងនឹងការប្រើប្រាស់រលកអាកាស ការប្រកមអាជីវកម្មកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ ដើម្បីពិនិត្យនិងដោះស្រាយបញ្ហាឬស្នើមតិជាមួយ កសថឆ. ដើម្បីពិចារណាតាមលក្ខណ្ឌដែល កសថឆ. បានកំណត់

(៥) សិក្សាបង្រួបបង្រួមនិងវិភាគពត៌មានទាក់ទងនឹងរលកអាកាស ការប្រើប្រាស់រលកអាកាស ការប្រកបអាជីវកម្មកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍

(៦) ទទួលខុសត្រូវការងាយរដ្ឋបាលរបស់ កសថឆ. កសថ. កថខ. និងគណៈកម្មការគ្រប់គ្រងមូលនិធិ

(៧) ការអនុវត្តន៍ផ្សេងៗតាម កសថឆ. កសថ. កថខ. បានប្រគល់

**មាត្រា ៥៨** អោយ កសថឆ. មានអំណាចចេញរបៀបឬប្រកាសទាក់ទងនឹងផ្នែករដ្ឋបាលទូទៅ ការគ្រប់គ្រងបុគ្គលិក ការងារថវិកា ហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិ និងការអនុវត្តន៍ផ្សេងៗរបស់ការិយាល័យកសថឆ. ដោយបូករូមជាមួយរឿងទាំងនេះដែល

(១) ការចែកការងារផ្ទៃក្នុងរបស់ការិយាល័យ កសថឆ.  និងក្របខណ្ឌទូនាទី

(២) ការកំណត់តំណែង ប្រាក់ខែ និងប្រាកបៀវត្តផ្សេងៗរបស់លេខាធិការ កសថឆ. បុគ្គលិករបស់ការិយាល័យ កសថឆ. រួមទាំងប្រាក់បៀវត្តនិងប្រាក់ចំណាយរបស់កម្មការផ្សេងនិងអនុកម្មការតាមព្រះរាជបញ្ញត្តិនេះ។

(៣) ការជ្រើសរើសឬការវាយតម្លៃចំណេះដឹងដើម្បីប្រយោជន៍ក្នុងការតែងតាំងអោយកាន់កាប់តំណែង ឬការតំឡើងប្រាក់ខែ លក្ខណ្ឌការបន្តកិច្ចសន្យាជួល ការចាយប្រាក់សំណងករណីបញ្ឈប់ការជួលដោយសារមិនជាប់ការវាយតម្លៃ។

(៤) ការគ្រប់គ្រងបុគ្គលិក រួមទាំងការដំណើរការផ្នែកវិន័យ ការបណ្តឹងឧទ្ធរណ៍

(៥) ការស្តីទីនិងការបំពេញទូនាទីជំនួស

(៦) ការកំណត់ឯកសណ្ឋាននិងសំលៀកបំពាក់របស់បុគ្គលិករបស់ការិយាល័យ កសថឆ.

(៧) ការជួលនិងការតែងតាំងបុគ្គលដើម្បីជាអ្នកជំនាញឬជាអ្នកជំនាញឯកទេសដែលជាប្រយោជន៍សម្រាប់ការបំពេញទូនាទីសម្រាប់ កសថឆ.  រួមទាំងអត្រាប្រាក់ឈ្នួល

(៨) ការគ្រប់គ្រងនិងការរៀបចំថវិកា ទ្រព្យសម្បត្តិ និងភស្តុភាររបស់ការិយាល័យ កសថឆ.

(៩) ការរៀបចំផលប្រយោជន៍និងការសង្គ្រោះផ្សេងៗ

របៀបឬប្រកាសតាមកថាខណ្ឌទីមួយ អោយប្រធានកម្មការជាអ្នកចុះហត្ថលេខា ហើយនៅពេលដែលបានប្រកាសក្នុងព្រះរាជក្រមហើយអោយចូលជាធរមាន។

**មាត្រា ៥៩** អោយការិយាល័យ កសថឆ. បង្ហាញពត៌មានទាក់ទងនិងការដំណើរការរបស់ កសថឆ. និងការិយាល័យ កសថឆ. អោយប្រជាជនបានជ្រាបតាមរយៈពត៌មានវិទ្យាឬវិធិការផ្សេងដែលគួរសម ដោយយ៉ាងហោចណាស់ត្រូវបង្ហាញពត៌មានដូចតទៅ

(១) ប័ណ្ណអនុញ្ញាតប្រកបអាជីវកម្មរបស់អ្នកកាន់ប័ណ្ណអនុញ្ញាតទាំងអស់ រួមទាំងលក្ខណ្ឌដែលកំណត់

(២) ចំណូលរបស់ការិយាល័យ កសថឆ. តាមមាត្រា ៦៥ សរុបជាខែ

(៣) ចំណាយសម្រាប់ការដំណើរការរបស់ កសថឆ. និងការិយាល័យ កសថឆ. សរុបជាខែ

(៤) ពត៌មានរបស់អត្រាប្រាក់ឈ្នួលរបស់កម្មការ កសថ. កថខ. អនុកម្មការ និងទីប្រឹក្សាផ្សេងៗ ដោយបង្ហាញជាម្នាក់ៗ

(៥) លទ្ធផលនៃការស្រាវជ្រាវនិងលទ្ធផលផ្សេងៗ ដែលបានជួលអោយអង្គភាពខាងក្រៅដំណើរការ

(៦) សំណុំរឿងដែលបណ្តឹង លទ្ធផលនៃការពិចារណាក្តីបណ្តឹងរបស់អ្នកបរិភោគនិងអ្នកកាន់ប័ណ្ណអនុញ្ញាតនិងចំនួនរឿងក្តីដែលមិនទាន់បានពិចារណា

(៧) ពត៌មាននៃការរៀបចំទិញឬជួលរបស់ការិយាល័យ កសថឆ. និងសន្យានានាដែលទាក់ទង

**មាត្រា ៦០** អោយការិយាល័យ កសថឆ. មានលេខាធិការ កសថឆ. មួយរូបទទួលខុសត្រូវការអនុវត្តការងាររបស់ការិយាល័យ កសថឆ. ដោយនៅក្រោមការបង្គាប់របស់ប្រធានកម្មការ និងជាមេបញ្ជាការរបស់បុគ្គលិករបស់ការិយាល័យ កសថឆ.

សម្រាប់កិច្ចការរបស់ការិយាល័យ កសថឆ. ដែលទាក់ទងនឹងបុគ្គលផ្សេង អោយលេខាធិការ កសថឆ. ជាតំណាងរបស់ការិយាល័យ កសថឆ. ដើម្បីលេខាធិការ កសថឆ. នឹងប្រគល់អំណាចអោយបុគ្គលអនុវត្តការងារជំនួសបាន ស្របទៅតាមបទដ្ឋានដែល កសថឆ. បានកំណត់ ដោយប្រកាសក្នុងរាជកិច្ច។ បទដ្ឋាននេះនឹងកំណត់ដោយបង្គាប់អោយលេខាធិការ កសថឆ. ត្រូវប្រគល់អំណាចទៅអោយបុគ្គលណាមួយមិនបានឡើយ។

**មាត្រា ៦១** អោយប្រធានកម្មការ ដោយការឯកភាពពី កសថឆ. ជាអ្នកតែងតាំងនិងតម្លក់លេខាធិការ កសថឆ.

លេខាធិការ កសថផ. ត្រូវមានអាយុមិនតិចជាងសាមសិបប្រាំឆ្នាំចាប់ពីថ្ងៃដែលតែងតាំងនិងត្រូវមានលក្ខណៈសម្បត្តិនិងមិនមានលក្ខណៈហាមឃាត់តាមមាត្រា ៧ រួមទាំងលក្ខណៈសម្បត្តិផ្សេងតាម កសថផ. បានកំណត់។

**មាត្រា ៦២** លេខាធិការ កសថផ. មានអាណត្តិក្នុងតំណែងមួយអាណត្តិប្រាំឆ្នាំចាប់តាំងពីថ្ងៃដែលបានការតែងតាំងហើយអាចត្រូវតែងតាំងបានទៀត ប៉ុន្តែមិនអាចនៅក្នុងតំណែងបានច្រើនជាងពីរអាណត្តិជាប់គ្នា។

**មាត្រា ៦៣** ក្រៅពីការផុតពីតំណែងតាមអាណត្តិតាមមាត្រា ៦២ លេខាធិការ កសថផ. អាចផុតពីតំណែងនៅពេលដែល

(១) ស្លាប់

(២) មានអាយុគ្រប់ហុកសិបឆ្នាំ

(៣) សុំចុះចេញ

(៤) ជាបុគ្គលក្ស័យធន

(៥) ត្រូវផ្តន់ទាទោសអោយជាប់គុកដោយដីកាដាច់ខាតអោយជាប់គុក

(៦) ខ្វះខាតលក្ខណៈសម្បត្តិឬមានលក្ខណៈត្រូវហាមឃាត់តាមមាត្រា ៦១ កថាខណ្ឌទីពីរ

(៧) កសថផ. មានមតិដោយមានសំលេងមិនតិចជាងពីរភាគបីរបស់ចំនួនកម្មការទាំងអស់អោយចុះចេញពីតំណែងដោយសារការមានកំហុសចំពោះមុខងារ ប្រព្រឹត្តិល្មើស អស់សម្ថភាព ឬមិនអាចបំពេញទួនាទីបាន។

**មាត្រា ៦៤** អោយលេខាធិការ កសថផ. និងបុគ្គលិករបស់ការិយាល័យ កសថផ. ជាមន្រ្តីសម្ថកិច្ចរបស់រដ្ឋតាមច្បាប់អមរដ្ឋធម្មនុញ្ញស្តីពីការការពារនិងបង្ក្រាបអំពើពុករលួយ។

បុគ្គលិករបស់ការិយាល័យ កសថផ. ត្រូវមានលក្ខណៈសម្បត្តិឬមិនមានលក្ខណៈត្រូវហាមឃាត់តាមរបៀបដែល កសថផ. បានកំណត់ ហើយត្រូវមិនមែនជាកម្មការ នាយក អ្នកគ្រប់គ្រង ទីប្រឹក្សា បុគ្គលិក អ្នកកាន់ភាគហ៊ុន ឬភាគហ៊ុនរបស់ក្រុមហ៊ុនឬសហគ្រាសនានាដែលប្រកបអាជីវកម្មកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ឬកិច្ចការទូរគមនាគមន៍។

អោយលេខាធិការ កសថផ. ជាអ្នកកាន់តំណែងខ្ពស់បំផុតតាមច្បាប់អមរដ្ឋធម្មនុញ្ញស្តីពីការការពារនិងបង្ក្រាបអំពើពុករលួយ។

សម្រាប់ការអនុវត្តតាមព្រះរាជបញ្ញត្តិនេះ អោយលេខាធិការ កសថផ. និងមន្ត្រីសម្ថកិច្ចជាបុគ្គលិកតាមច្បាប់ព្រហ្មទណ្ឌ។

**មាត្រា ៦៥** ចំណូលរបស់ការិយាល័យ កសថឆ. មានដូចតទៅ

(១) តម្លៃប័ណ្ណអនុញ្ញាតអោយប្រើប្រាស់រលកអាកាសនិងតម្លៃប័ណ្ណអនុញ្ញាតប្រកបអាជីវកម្មកិច្ចការតាមមាត្រា ៤២ កថាខណ្ឌទីពីរ និងមាត្រា ៤៥ កថាខណ្ឌទីបី។

(២) ចំណូលឬផលប្រយោជន៍ដែលបានមកពីការដំណើរការតាមសិទ្ធិអំណាចរបស់ កសថឆ. និងការិយាល័យ កសថឆ.

(៣) ចំណូលពីទ្រព្យរបស់ការិយាល័យ កសថឆ.

(៤) ប្រាក់ឬទ្រព្យដែលមានអ្នកបរិចាកអោយការិយាល័យ កសថឆ. តាមរបៀបដែល កសថឆ. បាបកំណត់ដើម្បីប្រើក្នុងការអនុវត្តន៍ការងាររបស់ការិយាល័យ កសថឆ.

(៥) ប្រាក់ទ្រទ្រង់ដែលរដ្ឋបាលរៀបចំអោយ

ចំណូលរបស់ កសថឆ. តាម (១) និង (២) នៅពេលដែលបានកាត់ចំណាយសម្រាប់ការដំណើរការរបស់ការិយាល័យ កសថឆ. ចំណាយនានាដែលចាំបាច់ ប្រាក់ដែលរៀបចំដើម្បីអោយមូលនិធិតាមមាត្រា ៥២ និងមូលនិធិអភិវឌ្ឍបច្ចេកទេសដើម្បីការអប់រំតាមច្បាប់ស្តីពីការអប់រំជាតិ បើនៅសល់អោយយកទៅជាចំណូលដែនដី។

ករណីដែលចំណូលរបស់ការិយាល័យ កសថឆ. មិនគ្រប់គ្រាន់សម្រាប់ចំណាយក្នុងការដំណើរការរបស់ កសថឆ. រួមទាំងចំណាយនានាដែលចាំបាច់ហើយមិនអាចរកចំណូលពីកន្លែងផ្សេងបាន។ រដ្ឋត្រូវរៀបចំថវិកាជាតិអោយការិយាល័យ កសថឆ. ស្មើនឹងចំនួនដែលចាំបាច់។

**មាត្រា ៦៦** ដើម្បីប្រយោជន៍ក្នុងការរៀបចំថវិកាជាតិអោយការិយាល័យ កសថឆ. តាមមាត្រា ៦៥ កថាខណ្ឌទីបី។ អោយការិយាល័យ កសថឆ. ស្នើថវិកាប្រាក់ចំណាយប្រចាំឆ្នាំដែលត្រូវសុំការទ្រទ្រង់ចំពោះគណៈរដ្ឋមន្ត្រី ដើម្បីរៀបចំថវិកាទ្រទ្រង់ការិយាល័យ កសថឆ. ចូលក្នុងពង្រាងព្រះរាជបញ្ញត្តិថវិកាប្រាក់ចំណាយប្រចាំឆ្នាំឬពង្រាងព្រះរាជបញ្ញត្តិថវិកាប្រាក់ចំណាយបន្ថែមតាមតែករណី។ ដោយគណៈរដ្ឋមន្ត្រីអាចមានមតិទាក់ទងនឹងការរៀបចំថវិការបស់ការិយាល័យ កសថឆ. ដាក់ក្នុងរាយការណ៍ការស្នើពង្រាងព្រះរាជបញ្ញត្តិថវិកាប្រាក់ចំណាយប្រចាំឆ្នាំឬពង្រាងព្រះរាជបញ្ញត្តិថវិកាប្រាក់ចំណាយបន្ថែមក៏បាន។

**មាត្រា ៦៧** អចលនទ្រព្យដែលការិយាល័យ កសថផ. បានមកពីការទិញដោយប្រាក់ចំណូលរបស់ការិយាល័យ កសថផ. តាមមាត្រា ៦៥ (១) (២) ឬ (៣) ឬមានអ្នកបរិចាកអោយតាម (៤) អោយទៅជាកម្មសិទ្ធិរបស់ការិយាល័យ កសថផ.

អចលនទ្រព្យដែលជារបស់ហ្លួងតាមច្បាប់ស្ដីពីរបស់ហ្លួងដែលនៅក្នុងការកាន់កាប់របស់ការិយាល័យ កសថផ .។ អោយការិយាល័យ កសថផ. មានអំណាចក្នុងការគ្រប់គ្រង ថែទាំ ប្រើប្រាស់ និងរកស៊ីបានតាមរបៀបដែល កសថផ . បានកំណត់។

ទ្រព្យរបស់ការិយាល័យ កសថផ. មិននៅក្នុងការទទួលខុសត្រូវក្នុងការបង្គាប់ក្ដី

**មាត្រា ៦៨** ការបញ្ជីគណនេយ្យរបស់ការិយាល័យ កសថផ. អោយរៀបចំតាមស្ដង់ដាសាកលរបស់សភាអ្នកពិនិត្យបញ្ជី និងត្រូវរៀបចំអោយមានការពិនិត្យផ្ទៃក្នុងទាក់ទងនឹងហិរញ្ញវត្ថុ បញ្ជីគណនេយ្យ និងភស្ដុភាររបស់ការិយាល័យ កសថផ. តាមរបៀបដែល កសថផ. បានកំណត់។

ការពិនិត្យតាមកថាខណ្ឌទីមួយ អោយមានគណៈកម្មការពិនិត្យផ្ទៃក្នុងចំនួនមិនតិចជាងបីនាក់និងមិនលើសប្រាំនាក់ ដែល កសថផ. តែងតាំងពីអ្នកវិជ្ជាជីវៈដែលមានចំណេះដឹងសម្រាប់ការពិនិត្យនិងមានគុណសម្បត្តិនិងមិនមានលក្ខណៈតាមមាត្រា ៧ និងមាត្រា ៨ ហើយអោយការិយាល័យ កសថផ. រៀបចំអោយមានសម្ដកិច្ចដែលពិនិត្យផ្ទៃក្នុងមានចំនួនតាមគួរសមនៅក្រោមបង្គាប់របស់គណៈកម្មការពិនិត្យផ្ទៃក្នុង ដើម្បីជំនួយការគណៈកម្មការពិនិត្យផ្ទៃក្នុងនៃការអនុវត្តតាមទួនាទី។

អោយគណៈកម្មការពិនិត្យផ្ទៃក្នុងមានសេរីភាពក្នុងការបំពេញទួនាទី និងអោយ កសថផ. លេខាធិការ កសថផ. និងបុគ្គលិករបស់ការិយាល័យ កសថផ. ជួយសម្រួលចំពោះគណៈកម្មការពិនិត្យផ្ទៃក្នុងនិងសម្ដកិច្ចដែលពិនិត្យផ្ទៃក្នុងតាមការស្នើសុំ។

អោយគណៈកម្មការពិនិត្យក្នុងរាយការណ៍លទ្ធផលការពិនិត្យជូន កសថផ. រៀងរាល់មួយរយប៉ែតសិបថ្ងៃ។

អាណត្តិក្នុងការកាន់តំណែង ការចុះចេញពីតំណែង និងការប្រជុំរបស់គណៈកម្មការពិនិត្យផ្ទៃក្នុងអោយត្រូវទៅតាមរបៀបដែល កសថផ. បានកំណត់។

**មាត្រា ៦៩** អោយការិយាល័យ កសថផ. រៀបចំតារាងតុល្យការ របាយការណ៍ហិរញ្ញវត្ថុ និងបញ្ជីគណនេយ្យក្នុងបុកសិបថ្ងៃរាប់តាំងពីផុតឆ្នាំបញ្ជីគណនេយ្យ។

រាល់ឆ្នាំ អោយការិយាល័យពិនិត្យហិរញ្ញវត្ថុដែនដីជាអ្នកពិនិត្យបញ្ជីគណនេយ្យនិងវាយតម្លៃការចំណាយប្រាក់និងទ្រព្យរបស់ការិយាល័យ កសថផ. ដោយពិគ្រោះប្រសិទ្ធិភាពក្នុងការចំណាយទឹកប្រាក់រួមទាំងបង្ហាញមតិបញ្ជាក់ថាការចំណាយទឹកប្រាក់នោះត្រូវទៅតាមគោលដៅ ហើយមានលទ្ធផលតាមគោលដៅប៉ុណ្ណា។ និងកត់ត្រាធ្វើរបាយការណ៍លទ្ធផលជូន កសថផ. គណៈរដ្ឋមន្ត្រី និងរដ្ឋសភា។

អោយការិយាល័យ កសថផ. ជាអង្គភាពទទួលការពិនិត្យតាមច្បាប់អមរដ្ឋធម្មនុញ្ញស្តីពីការពិនិត្យហិរញ្ញវត្ថុដែនដី។

ជំពូក ៦

ការតាមដាន ពិនិត្យ និងវាយតម្លៃការដំណើរការនិងការគ្រប់គ្រងការងារ

---

**មាត្រា ៧០** អោយមានគណៈកម្មការតាមដាននិងវាយតម្លៃការអនុវត្តការងារមួយក្រុម រួមមាន ប្រធានកម្មការមួយរូបនិងកម្មការផ្សេងទៀតបួនរូប ដែលត្រូវមានលក្ខណៈសម្បត្តិដូចតទៅ

(១) ជាអ្នកដែលមានស្នាដៃឬមានចំណេះដឹង និងមានជំនាញឬបទពិសោធន៍ផ្នែកកិច្ចការផ្សាយសំលេង ចំនួនមួយរូប និងផ្នែកកិច្ចការទូរទស្សន៍ ចំនួនមួយរូប

(២) ជាអ្នកដែលមានស្នាដៃឬមានចំណេះដឹង និងមានជំនាញឬបទពិសោធន៍ផ្នែកកិច្ចការទូរគមនាគមន៍ ចំនួនមួយរូប

(៣) ជាអ្នកមានស្នាដៃនិងបទពិសោធន៍ផ្នែកការពារអ្នកបរិភោគ ចំនួនមួយរូប

(៤) ជាអ្នកមានស្នាដៃនិងបទពិសោធន៍ផ្នែកការជំរុញសិទ្ធិនិងសេរីភាពរបស់ប្រជាជនចំនួនមួយរូប

អោយប្រធានព្រឹទ្ធសភារៀបចំអោយមានការជ្រើសរើសបុគ្គលិកដែលគួរសមនឹងត្រូវស្នើឈ្មោះជាកម្មការចំនួនពីរដងរបស់ចំនួនកម្មការតាមកថាខណ្ឌទីមួយ ដើម្បីស្នើអោយព្រឹទ្ធសភាពិចារណាជ្រើសរើស អោយត្រូវទៅតាមលក្ខណ្ឌនិងវិធិការដែលប្រធានព្រឹទ្ធសភាបានកំណត់។

អោយអ្នកដែលត្រូវបានជ្រើសរើសជាកម្មការប្រជុំរួមដើម្បីជ្រើសរើសប្រធានកម្មការ

**មាត្រា ៧១** កម្មការតាមដាននិងវាយតម្លៃការអនុវត្តការងារមានអាណត្តិបីឆ្នាំ ហើយមិនអាចកាន់តំណែងជាប់គ្នាពីរអាណត្តិបានឡើយ។

កម្មការតាមកថាខណ្ឌមួយត្រូវមិនមែនជាកម្មការ កសថផ. កសថ. កថខ. អនុកម្មការ លេខាធិការ កសថផ. បុគ្គលិករបស់ការិយាល័យ កសថផ. ហើយអោយអនុវត្តតាមមាត្រា ៧ មាត្រា ៨ និងមាត្រា ២០ (១) (៣) (៤) និង (៥) ជាការអនុលោម។

ករណីដែលកម្មការតាមដាននិងវាយតម្លៃការអនុវត្តការងារចេញពីតំណែងដោយសារមូលហេតុផ្សេងដែលមិនមែនជាការចេញតាមអាណត្តិ។ អោយកម្មការដែលនៅសល់បំពេញទួនាទីជាបន្ត ហើយអោយចាត់ទុកថាគណៈកម្មការតាមដាននិងវាយតម្លៃការអនុវត្តការងារប្រកបដោយកម្មការដែលមានសល់ លើកលេងតែមានកម្មការមិនដល់បីនាក់។

វិធីការប្រជុំនិងការបញ្ចេញមតិអោយស្របទៅតាមបទបញ្ញូដែលគណៈកម្មការតាមដាននិងវាយតម្លៃការអនុវត្តការងារបានកំណត់។

ថ្លៃឈ្នួលនិងប្រាក់ចំណាយផ្សេងៗ សម្រាប់ការជ្រើសរើសនិងការអនុវត្តការងាររបស់កម្មការតាមដាននិងវាយតម្លៃការអនុវត្តការងារអោយស្របទៅតាមបទបញ្ញូដែល កសថផ. បានកំណត់។

**មាត្រា ៧២** អោយគណៈកម្មការតាមដាននិងវាយតម្លៃការអនុវត្តការងារ មានសិទ្ធិអំណាចតាមដាន ពិនិត្យ និងវាយតម្លៃការដំណើរការនិងការគ្រប់គ្រងការងាររបស់ កសថផ. កសថ. កថខ. ការិយាល័យ កសថផ. និងលេខាធិការ កសថផ. ហើយរាយការណ៍អោយ កសថផ. បានជ្រាបក្នុងកៅសិបថ្ងៃចាប់ពីថ្ងៃផុតឆ្នាំបញ្ជី។ ហើយអោយ កសថផ. រាយការណ៍ជូនរដ្ឋសភារួមទាំងរាយការណ៍លទ្ធផលការអនុវត្តការងារប្រចាំឆ្នាំរបស់ កសថផ. តាមមាត្រា ៧៦ និងបង្ហាញរាយការណ៍នោះអោយប្រជាជនបានជ្រាបតាមរយៈពត៌មានវិទ្យារបស់ កសថផ. ឬតាមរយៈផ្សេងៗ។

ការវាយតម្លៃតាមកថាខណ្ឌមួយត្រូវវាយតម្លៃតាមការណ៍ពិតហើយត្រូវមានការស្តាប់មតិពីអ្នកដែលមានផលប្រយោជន៍រួមជាមួយដែរ។

គណៈកម្មការអាចប្រគល់អោយអង្គភាពឬអង្គការដែលមានជំនាញជាអ្នកបង្រួបបង្រួមពត៌មានពិគ្រោះ និងវាយតម្លៃដើម្បីផលប្រយោជន៍ក្នុងការរៀបចំធ្វើរបាយការណ៍។

**មាត្រា ៧៣** របាយការណ៍តាមមាត្រា ៧២ យ៉ាងហោចសាច់ក្តីត្រូវមានដូចតទៅ

(១) លទ្ធផលនៃការធ្វើការរបស់ កសថផ. កសថ. កថខ. ការិយាល័យ កសថផ. និងលេខាធិការ កសថផ.

(២) របាយការណ៍ការពិតឬចំណុចសង្ស័យពីការអនុវត្តតាមសិទ្ធិអំណាចរបស់ កសថផ. នៅផ្នែកដែលទាក់ទងនឹងការបំពេញទួនាទីប្រកបដោយប្រសិទ្ធិភាពនិងស្របទៅនឹងគោលនយោបាយរបស់រដ្ឋបាល រួមទាំងមតិនិងការក្តីណែនាំ។

(៣) មតិទាក់ទងនឹងរបាយការណ៍ប្រចាំឆ្នាំដែល កសថផ. បានរៀបចំធ្វើតាមមាត្រា ៧៦

(៤) រឿងផ្សេងៗ ដែលឃើញថាគួររាយការណ៍អោយ កសថផ. រដ្ឋសភា ឬប្រជាជនបានជ្រាប

អោយ កសថផ. កសថ. កថខ. ការិយាល័យ កសថផ. និងលេខាធិការ កសថផ. សហការនិងសម្រួលការងារចំពោះគណ:កម្មការតាមដាននិងវាយតម្លៃការអនុវត្តការងារតាមការស្នើសុំ។

## ជំពូក ៧

## សម្ព័ន្ធភាពជាមួយរដ្ឋបាលនិងរដ្ឋសភា

---

**មាត្រា ៧៤** ក្នុងការអនុវត្តតាមសិទ្ធិអំណាច កសថផ. ត្រូវអនុវត្តអោយស្របទៅនឹងគោលនយោបាយដែលគណ:រដ្ឋមន្ត្រីបានប្រកាសចំពោះរដ្ឋសភា។

**មាត្រា ៧៥** ករណីដែលត្រូវមានការចរចាឬឯកភាពគ្នារវាងរដ្ឋបាលថៃនិងរដ្ឋបាលប្រទេសផ្សេងឬអង្គការរវាងប្រទេស ក្នុងរឿងដែលទាក់ទងនឹងការគ្រប់គ្រងរលកអាកាស កិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ កិច្ចការទូរគមនាគមន៍ ឬកិច្ចការផ្សេងដែលទាក់ទង កសថផ. និងការិយាល័យ កសថផ. មានទួនាទីត្រូវផ្តលពត៌មាននិងរួមដំណើរការតាមដែលរដ្ឋបាលបានជូនដំណឹងអោយជ្រាប។

**មាត្រា ៧៦** អោយ កសថផ. រៀបចំធ្វើរបាយការណ៍ការអនុវត្តការងារប្រចាំឆ្នាំក្នុងផ្នែកគ្រប់គ្រងរលកអាកាស កិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ តាមតែករណី។ ដែលត្រូវបង្ហាញពត៌មានគម្រោងការនិងលទ្ធផលការអនុវត្តការងារ ពត៌មានទាក់ទងនឹងការគ្រប់គ្រងរលកអាកាស ការរៀបចំរលកអាកាស ការប្រកបអាជីវកម្មកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ តាមតែករណី។ និងគម្រោងការដំណើរការបន្តនាំទៅស្នើជូនគណ:រដ្ឋមន្ត្រីក្នុងមួយរយម្ភៃថ្ងៃចាប់ពីថ្ងៃដាច់ឆ្នាំបញ្ជី និងបង្ហាញអោយប្រជាជនបានជ្រាប។

របាយការណ៍ការអនុវត្តការងារប្រចាំឆ្នាំតាមកថាខណ្ឌទីមួយ យ៉ាងហោចណាស់ត្រូវមានដូចតទៅ

(១) សមិទ្ធិផលរបស់ កសថផ. ក្នុងឆ្នាំកន្លងទៅប្រៀបធៀបជាមួយគម្រោងការឬផែនការដែលបានកំណត់ទុក

(២) ផែនការ គម្រោងការ និងគម្រោងថវិកាសម្រាប់ឆ្នាំបន្ទាប់

(៣) ថវិកានិងរបាយការនណ៍របស់អ្នកពិនិត្យបញ្ជី របាយការណ៍ការពិនិត្យផ្ទៃក្នុង

(៤) បញ្ហានិងឧបសគ្គក្នុងការប្រកបអាជីវកម្មកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ប្រភេទនានា ដែលមានសារៈសំខាន់សម្រាប់ប្រជាជន

(៥) គុណភាពនិងអត្រាតម្លៃការប្រើសេវាទូរគមនាគមន៍ប្រភេទនានា ដែលមានសារៈសំខាន់សម្រាប់ប្រជាជន

(៦) ប្រសិទ្ធិភាពក្នុងការពិចារណារឿងបណ្តឹងពីអ្នកបរិភោគ

(៧) ប្រសិទ្ធិភាពរបស់មូលនិធិតាមមាត្រា ៥២

(៨) របាយការណ៍ទាក់ទងនឹងការប្រកួតប្រជែងក្នុងទីផ្សារនៃការប្រកបអាជីវកម្មកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ប្រភេទនានា រួមទាំងចំណុចសង្ស័យទាក់ទងនឹងការប្រព្រឹត្តដែលមានលក្ខណៈផ្តាច់មុខកិច្ចការដែលមានផលប៉ះពាល់នឹងប្រយោជន៍របស់រដ្ឋនិងប្រជាជន។

នាយករដ្ឋមន្រ្តី សភាតំណាងរាស្រ្ត និងព្រឹទ្ធសភា អាចសុំអោយ កសថឆ. ឬលេខាធិការ កសថឆ. ពន្យល់រៀបរាប់ការដំណើរការក្នុងរឿងណាមួយជាលាយលក្ខណ៍អក្សរឬសុំអោយមកពន្យល់ដោយវាចាក៏បាន។

## ជំពូក ៨
## ការកំណត់ទោស

---

**មាត្រា ៧៧** អ្នកប្រកបអាជីវកម្មកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ ឬកិច្ចការទូរគមនាគមន៍ អ្នកណាបានទទួលបញ្ជាតាមមាត្រា ៣១ កថាខណ្ឌទីពីរ ហើយមិនអនុវត្តតាម អោយ កសថឆ. មានអំណាចពិន័យមិនលើសប្រាំលានបាទ និងពិន័យមួយថ្ងៃមិនលើសពីមួយសែនបាទដរាបដែលមិនទាន់អនុវត្តតាមបទបញ្ជា។

**មាត្រា ៧៨** អ្នកប្រើរលកអាកាសដើម្បីកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ ឬកិច្ចការទូរគមនាគមន៍ ដោយមិនបានទទួលការអនុញ្ញាតតាមមាត្រា ៤១ កថាខណ្ឌទីមួយ ឬមាត្រា ៤៥ កថាខណ្ឌទីមួយ អ្នកនោះត្រូវមានទោសតាមដែលបានបញ្ញត្តិតាមមាត្រា ៦៦ នៃព្រះរាជបញ្ញត្តិការប្រកបអាជីវកម្មកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍ ព.ស.២៥៥១ ឬតាមមាត្រា ៦៧ នៃព្រះរាជបញ្ញត្តិអមកិច្ចការទូរគមនាគមន៍ ព.ស.២៥៤៤ តាមតែករណី។

**មាត្រា ៧៩** មន្ត្រីសម្ថកិច្ច កសថឆ. ឬអ្នកដែលប្រើអំណាចរបស់ កសថឆ. ដែលដឹងឬទទួលបណ្តឹងពីបុគ្គលថាមានការប្រើរលកអាកាសដែលជាការល្មើសឬមិនអនុវត្តតាមព្រះរាជបញ្ញត្តិនេះ។ បើមិនបានដំណើរការអនុវត្តអោយស្របតាមព្រះរាជបញ្ញត្តិនេះ និងការប្រព្រឹត្តិនោះមិនខុសតាមមាត្រា ១៥៧ នៃច្បាប់ព្រហ្មទណ្ឌ។ មន្ត្រីសម្ថកិច្ច កសថឆ. ឬអ្នកដែលប្រើអំណាចរបស់ កសថឆ. ប្រព្រឹត្តិល្មើសនោះ ត្រូវផ្តន់ទាទោសមិនលើសបីឆ្នាំឬពិន័យមិនលើសប្រាំមួយម៉ឺនបាទឬទាំងពីរ។

អន្តរប្បញ្ញត្តិ

---

**មាត្រា ៨០** ក្នុងអំឡុងពេលដែលការតែងតាំង កសថឆ. តាមព្រះរាជបញ្ញត្តិនេះមិនទាន់រួចរាល់។ អោយគណៈកម្មការកិច្ចការទូរគមនាគមន៍ជាតិដែលត្រូវតែងតាំងតាមព្រះរាជបញ្ញត្តិអង្គការរៀបចំរលកអាកាសនិងគ្រប់គ្រងកិច្ចការវិទ្យុផ្សាយសំលេង វិទ្យុទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ ព.ស.២៥៤៣ នៅបំពេញទូនាទីជា កសថឆ. បន្ត។ ប៉ុន្តែផ្នែកដែលទាក់ទងនឹងការប្រកបអាជីវកម្មកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍តាមច្បាប់ស្តីពីការប្រកបអាជីវកម្មកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍អោយស្របទៅតាមច្បាប់នោះ

នៅពេលដែល កសថឆ. មានការតែងតាំងហើយ អោយគណៈកម្មការកិច្ចការទូរគមនាគមន៍ជាតិតាមកថាខណ្ឌទីមួយចុះចេញពីតំណែង។

**មាត្រា ៨១** អោយគណៈកម្មការតាមព្រះរាជបញ្ញត្តិការប្រកបអាជីវកម្មកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍ ព.ស.២៥៥១ គណៈកម្មការតាមព្រះរាជបញ្ញត្តិការប្រកបអាជីវកម្មកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍ ព.ស.២៥៤៤ និងគណៈកម្មការកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍ជាតិតាមមាត្រា ៦១ នៃព្រះរាជបញ្ញត្តិអង្គការផ្សាយសំលេងនិងផ្សាយរូបភាពសាធារណៈនៃប្រទេសថៃ ព.ស.២៥៥១ មានន័យជា កសថឆ. តាមព្រះរាជបញ្ញត្តិនេះ។

បណ្តូសិទ្ធិអំណាចរបស់រដ្ឋមន្ត្រី អគ្គនាយកដ្ឋានទូរលេខ និងសម្ថកិច្ចអ្នកចេញប័ណ្ណអនុញ្ញាត តាមច្បាប់ស្តីពីវិទ្យុគមនាគមន៍ជាសិទ្ធិអំណាចរបស់ កសថឆ. តាមព្រះរាជបញ្ញត្តិនេះ។

**មាត្រា ៨២** នៅពេលដែលមានការតែងតាំង កសថឆ. ហើយ។ អោយរាជការ សហគ្រាសរដ្ឋ អង្គភាពរដ្ឋ ឬបុគ្គលណាដែលទទួលបានការរៀបចំរលកអាកាសឬប្រើប្រាស់រលកអាកាសដើម្បីប្រកបអាជីវកម្មកិច្ចការផ្សាយសំលេង កិច្ចការទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ ក្នុងថ្ងៃដែលព្រះរាជបញ្ញត្តិជាធរមាន មានទូនាទីបង្ហាញពត៌មានការ

ប្រើប្រាស់រលកអាកាស រួមទាំងមូលហេតុភាពចាំបាច់ក្នុងការកាន់កាប់រលកអាកាសចំពោះ កសថឆ. តាមលក្ខណ្ឌនិងរយៈពេលដែល កសថឆ. បានកំណត់។

ការអនុវត្តតាមកថាខណ្ឌទីមួយ អោយរាជការ សហគ្រាសរដ្ឋ អង្គភាពរដ្ឋប្រាប់ពត៌មានទាក់ទងនឹងការអនុញ្ញាត សម្បទាន ឬកិច្ចសន្យា រួមទាំងរយៈពេលកិច្ចសន្យានិងថ្លៃសម្បទានឬថ្លៃផ្សេងៗ តាមការអនុញ្ញាត សម្បទាន ឬកិច្ចសន្យានោះចំពោះ កសថឆ. តាមលក្ខណ្ឌនិងវិធិការដែល កសថឆ.បានកំណត់។ និងអោយ កសថឆ. ពិនិត្យការអនុញ្ញាត សម្បទាន ឬកិច្ចសន្យានោះ ទួមទាំងបង្ហាញពត៌មាននិងលទ្ធផលនៃការពិនិត្យអោយទីសាធារណៈបានជ្រាប។

**មាត្រា ៨៣** អ្នកដែលទទួលបានការរៀបចំរលកអាកាសឬប្រើប្រាស់រលកអាកាសដើម្បីការប្រកបអាជីវកម្មកិច្ចការផ្សាយសំលេងឬកិច្ចការទូរទស្សន៍ដែលស្របច្បាប់និងបានអនុវត្តតាមមាត្រា ៨២ ហើយ។ អោយចាត់ទុកថាត្រូវបានការអនុញ្ញាតពី កសថឆ. ហើយអោយ កសថឆ. គ្រប់គ្រងអោយអ្នកដែលទទួលបានការរៀបចំរលកអាកាសឬប្រើប្រាស់រលកអាកាសអនុវត្តតាមព្រះរាជបញ្ញត្តិនេះ ច្បាប់ផ្សេង និងតាមលក្ខណ្ឌដែល កសថឆ. បានកំណត់ រហូតដល់គ្រប់កំណត់ដែលត្រូវបញ្ជូនរលកអាកាសវិញតាមកថាខណ្ឌទីបី។

តាមមាត្រា ៨៣ មិនអោយអនុវត្តជាមួយរាជការឬសហគ្រាសរដ្ឋដែលយករលកអាកាសដែលទទួលបានទៅអោយអ្នកផ្សេងប្រកបអាជីវកម្មដោយការអនុញ្ញាត សម្បទាន ឬតាមកិច្ចសន្យាដែលស្របច្បាប់។ អោយអ្នកដែលបានការអនុញ្ញាត សម្បទាន ឬកិច្ចសន្យាវិនិយោគកិច្ចការបន្តបានទ្រឹមអំឡុងពេលដែលនៅសល់តាមការអនុញ្ញាត សម្បទាន ឬកិច្ចសន្យានោះ។

អោយ កសថឆ. កំណត់រយៈពេលដែលច្បាស់លាស់ក្នុងការអោយអ្នកដែលបានការអនុញ្ញាតប្រើប្រាស់រលកអាកាសបញ្ជូមរលកអាកាសវិញ។ ដើម្បីយកទៅរៀបចំជាថ្មីឬកែសម្រួលការប្រើប្រាស់រលកអាកាសតាមដែលបានកំណត់ទុកក្នុងគម្រោងគំរូការគ្រប់គ្រងរលកអាកាសតាមមាត្រា ៤៨ ដោយគិតពីប្រយោជន៍និងភាពចាំបាច់ក្នុងការប្រកបអាជីវកម្មនិងការប្រើរលកអាកាស ដោយនាំយកមូលហេតុចាំបាច់ក្នុងការគ្រប់គ្រងរលកអាកាសតាមដែលបានថែងក្នុងមាត្រា ៨២ មករួមពិចារណា។

**មាត្រា ៨៤** អ្នកដែលទទួលបានការរៀបចំរលកអាកាសឬប្រើរលកអាកាសដើម្បីកិច្ចការទូរគមនាគមន៍ដែលស្របច្បាប់ហើយបានអនុវត្តតាមមាត្រា ៨២ ហើយ។ អោយចាត់ទុកថាបានការអនុញ្ញាតពី កសថឆ.។ ហើយអោយ កសថឆ. គ្រប់គ្រងអោយអ្នកដែលទទួលបានការរៀបចំរលកអាកាសឬប្រើប្រាស់រលកអាកាសអនុវត្តតាមព្រះរាជបញ្ញត្តិ

នេះ ច្បាប់ផ្សេង និងតាមលក្ខណ្ឌ ដែល កសថឆ. បានកំណត់ រហូតដល់គ្រប់កំណត់ដែលត្រូវបញ្ជូនរលកអាកាសវិញតាមកថាខណ្ឌទីបួន។

តាមមាត្រា ៤៦ មិនអោយអនុវត្តជាមួយសហគ្រាសរដ្ឋដែលយករលកអាកាសដែលទទួលបានទៅអោយអ្នកផ្សេងវិនិយោគកិច្ចការដោយការអនុញ្ញាត សម្បទាន ឬតាមកិច្ចសន្យាដែលស្របច្បាប់។ និងអោយអ្នកដែលបានការអនុញ្ញាត សម្បទាន ឬកិច្ចសន្យាវិនិយោគកិច្ចការបន្តបានទ្រឹមអំឡុងពេលដែលនៅសល់តាមការអនុញ្ញាត សម្បទាន ឬកិច្ចសន្យានោះ។

នៅពេលដែលផុតរយៈពេលបីឆ្នាំចាប់តាំងពីព្រះរាជបញ្ញត្តិនេះចូលជាធរមាន អោយសហគ្រាសរដ្ឋនាំប្រាក់ចំណូលពីការវិនិយោគចំណែកដែលបានពីការអនុញ្ញាត សម្បទាន ឬកិច្ចសន្យាតាមកថាខណ្ឌទីពី ដោយមិនថានឹងដំណើរការទាំងអស់ ឬមួយចំណែក ដោយកាត់ប្រាក់ចំណាយដូចតទៅ។ ហើយចំណែកដែលសល់អោយបញ្ជូន កសថឆ. និងអោយ កសថឆ. នាំប្រាក់ចំណូលទាំងនោះទៅជាចំណូលរបស់ដែនដី។

(១) ថ្លៃប័ណ្ណអនុញ្ញាតប្រកបអាជីវកម្ម ចំពោះផ្នែកដែលគិតទ្រឹមចំណូលដែលមកពីការអនុញ្ញាត សម្បទាន ឬកិច្ចសន្យា

(២) ថ្លៃចំណាយដើម្បីគាំទ្រការរៀបចំអោយមានសេវាទូរគមនាគមន៍ និងបំរើសេវាដើម្បីសង្គមតាមគោលនយោបាយរដ្ឋបាល និងតាមមាត្រា ៥០ ការ ចំពោះផ្នែកដែលគិតទ្រឹមចំណូលដែលមកពីការអនុញ្ញាត សម្បទាន ឬកិច្ចសន្យា

(៣) ថ្លៃចំណាយដែលមកពីការដំណើរការតាមការអនុញ្ញាត សម្បទាន ឬកិច្ចសន្យា តាមដែលក្រសួងហិរញ្ញវត្ថុបានកំណត់

អោយ កសថឆ. កំណត់រយៈពេលដែលច្បាស់លាស់ក្នុងការអោយអ្នកដែលទទួលបានរលកអាកាសឬប្រើប្រាស់រលកអាកាស ជូនរលកអាកាសវិញដើម្បីនាំទៅរៀបចំថ្មីឬកែសម្រួលការប្រើប្រាស់រលកអាកាសតាមដែលបានកំណត់ក្នុងគម្រោងគំរូការគ្រប់គ្រងរលកអាកាសតាមមាត្រា ៤៨ ដោយយកមាត្រា ៨៣ កថាខណ្ឌទីបី មកអនុវត្តជាការអនុលោម។

**មាត្រា ៨៥** ក្នុងអាណត្តិចាប់ផ្តើមមិនអោយនាំយកមាត្រា ៤៩ ទាក់ទងនឹងការរៀបចំអោយប្រជាជនបានប្រើប្រាស់រលកអាកាសក្នុងកិច្ចការទូរទស្សន៍មិនតិចជាងម្ភៃភាគរយមកអនុវត្ត។ លុះត្រាតែកសថឆ. បានប្រកាសអោយប្រើប្រព័ន្ធការទទួលសេវាវិទ្យុទូរទស្សន៍ក្នុងប្រព័ន្ធឌីជីថលហើយ។

អោយ កសថឆ. រៀបចំអោយមានគម្រោងគំរូការគ្រប់គ្រងរលកអាកាសតាមមាត្រា ៤៨ ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីមានការតែងតាំង កសថឆ. ហើយ។ ដោយគម្រោងនោះត្រូវកំណត់អោយមានការកំណត់រយៈពេលក្នុងការប្តូរប្រព័ន្ធទទួលសេវាវិទ្យុទូរទស្សន៍ក្នុងប្រព័ន្ធឌីជីថលនិងកំណត់ពេលទាក់ទងនឹងការរៀបចំអោយប្រជាជនបានប្រើប្រាស់រលកអាកាសក្នុងកិច្ចការទូរទស្សន៍ផងដែរ។

ក្រោយពីប្រកាសអោយប្រើគម្រោងគំរូការគ្រប់គ្រងរលកអាកាសហើយ។ ក្នុងអំឡុងពេលដែលមិនទាន់បានប្រកាសអោយប្រើប្រព័ន្ធការផ្ញើនិងបញ្ជូនសេវាវិទ្យុទូរទស្សន៍ក្នុងប្រព័ន្ធឌីជីថល។ អោយ កសថឆ. រៀបចំរលកអាកាសអោយប្រជាជនបានប្រើប្រាស់ក្នុងកិច្ចការទូរទស្សន៍ជាបណ្តោះអាសន្នចំពោះតំបន់ដែលមានរលកអាកាសគ្រប់គ្រាន់សម្រាប់ការរៀបចំ។

**មាត្រា ៨៦** អ្នកកាន់ប័ណ្ណអនុញ្ញាតប្រកបអាជីវកម្មកិច្ចការទូរគមនាគមន៍ដែលគណៈកម្មការកិច្ចការទូរគមនាគមន៍ជាតិបានប្រគល់អោយដំណើរការរៀបចំអោយមានសេវាទូរគមនាគមន៍មូលដ្ឋាននិងសេវាដើម្បីសង្គម តាមព្រះរាជបញ្ញត្តិការប្រកបអាជីវកម្មកិច្ចការទូរគមនាគមន៍ ព.ស.២៥៤៤ មុនព្រះរាជបញ្ញត្តិនេះចូលជាធរមាន។ អោយបានការលើកលេងមិនចាំបាច់នាំចំណូលចូលមូលនិធិតាមមាត្រា ៥០ រហូតដល់ផុតរយៈពេលតាមដែលបានកំណត់ក្នុងប្រកាសគណៈកម្មការកិច្ចការទូរគមនាគមន៍ជាតិ ស្តីពី លក្ខណ្ឌ វិធីការ និងគោលការណ៍ក្នុងការរៀបចំអោយមានសេវាទូរគមនាគមន៍មូលដ្ឋាននិងសេវាដើម្បីសង្គម។

**មាត្រា ៨៧** ប័ណ្ណអនុញ្ញាតដែលចេញដោយស្របច្បាប់តាមព្រះរាជបញ្ញត្តិវិទ្យុទូរគមនាគមន៍ ព.ស.២៤៩៨ ព្រះរាជបញ្ញត្តិអង្គការរៀបចំរលកអាកាសនិងគ្រប់គ្រងកិច្ចការវិទ្យុសំលេង វិទ្យុទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ ព.ស.២៥៤៣ ព្រះរាជបញ្ញត្តិការប្រកបអាជីវកម្មវិទ្យុសំលេងនិងទូរទស្សន៍ ព.ស.២៥៥១ និងព្រះរាជបញ្ញត្តិការប្រកបអាជីវកម្មទូរគមនាគមន៍ ព.ស.២៥៤៤ មុនថ្ងៃដែលព្រះរាជបញ្ញត្តិនេះចូលជាធរមាន អោយប្រើបានរហូតដល់ផុតកំណត់ ហើយចាត់ទុកជាប័ណ្ណអនុញ្ញាតដែលចេញតាមព្រះរាជបញ្ញត្តិនេះ ដោយអោយ កសថឆ. គ្រប់គ្រងអោយអ្នកកាន់ប័ណ្ណអនុញ្ញាតអនុវត្តតាមព្រះរាជបញ្ញត្តិនេះ ច្បាប់នានាដែលទាក់ទង និងតាមលក្ខណ្ឌដែល កសថឆ. បានកំណត់

ប័ណ្ណអនុញ្ញាតតាមកថាខណ្ឌទីមួយដែលផ្តល់សិទ្ធិក្នុងការគ្រប់គ្រងឬប្រើប្រាស់រលកអាកាសហើយមិនបានកំណត់ថ្ងៃផុតកំណត់។ អោយនៅតែប្រើបានលុះដល់ កសថផ. បានកំណត់អោយប័ណ្ណនោះផុតកំណត់ ដោយនាំយកតាមមាត្រា ៨៣ កថាខណ្ឌទីបីមកអនុវត្តដោយអនុលោម។

**មាត្រា ៨៨** ក្នុងមួយរយម្ភៃថ្ងៃចាប់ពីព្រះរាជបញ្ញត្តិនេះចូលជាធរមាន អោយ កសថផ.ចេញប័ណ្ណអនុញ្ញាតអោយប្រើប្រាស់រលកអាកាសនិងប័ណ្ណអនុញ្ញាតប្រកបអាជីវកម្មកិច្ចការតាមច្បាប់ស្តីពីការប្រកបអាជីវកម្មកិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍ជូនអង្គការផ្សាយសំលេងនិងផ្សាយរូបភាពសាធារណៈនៃប្រទេសថៃ តាមលក្ខណៈនិងប្រភេទនៃការប្រកបអាជីវកម្ម រួមទាំងក្របខណ្ឌក្នុងការបំរើសេវា។

ការប្រើរលកអាកាសដើម្បីប្រកបអាជីវកម្មបន្ថែមពីដែលបានការអនុញ្ញាតតាមកថាខណ្ឌទីមួយ ត្រូវស្របទៅតាមគម្រោងគំរូការគ្រប់គ្រងរលកអាកាស និងត្រូវបានការអនុញ្ញាតពី កសថផ.។ ក្នុងនេះ កសថផ. អាចកំណត់លក្ខណ្ឌនានាដើម្បីប្រយោជន៍សាធារណៈក៏បាន។

ការប្រកបអាជីវកម្មរបស់អង្គការផ្សាយសំលេងនិងផ្សាយរូបភាពសាធារណៈនៃប្រទេសថៃ អោយនៅក្រោមព្រះរាជបញ្ញត្តិនេះដោយមិនទាស់នឹងច្បាប់ស្តីពីអង្គការផ្សាយសំលេងនិងផ្សាយរូបភាពនៃប្រទេសថៃ។

ក្នុងអំឡុងពេលដែលមិនទាន់បានប័ណ្ណអនុញ្ញាតតាមកថាខណ្ឌទីមួយ អោយអង្គការផ្សាយសំលេងនិងផ្សាយរូបភាពសាធារណៈនៃប្រទេសថៃប្រកបអាជីវកម្មបន្តទៅបាន។

**មាត្រា ៨៩** អោយផ្ទេរបណ្តកិច្ចការ ទ្រព្យសម្បត្តិ សិទ្ធិ ទូនាទី ជំពាក់ បុគ្គលិក និងប្រាក់ថវិកា របស់ការិយាល័យគណៈកម្មការកិច្ចការទូរគមនាគមន៍ជាតិដែលមាននៅអោយទៅជារបស់ការិយាល័យ កសថផ. តាមព្រះរាជបញ្ញត្តិនេះ។

អោយបុគ្គលិកដែលត្រូវផ្ទេរតាមកថាខណ្ឌទីមួយបានទទួលប្រាក់ខែ ប្រាក់តំណែងឬថ្លៃឈ្នួលរួមទាំងសិទ្ធិនានាស្មើនឹងដែលធ្លាប់បានទទួលជាបណ្តោះអាសន្នរហូតដល់បានតែងតាំងអោយកាន់តំណែងក្នុងការិយាល័យ កសថផ.។ ប៉ុន្តែមិនអាចតែងតាំងអោយទទួលប្រាក់ខែឬប្រាក់ឈ្នួលតិចជាងដែលធ្លាប់ទទួលបានឡើយ។

ករណីដែលបុគ្គលិកមួយណានៅក្រោមរបៀបឬកិច្ចសន្យាជួលដែលមិនបានកំណត់រយៈពេលក្នុងការជួល មិនអោយចាត់ទុកថាការជួលនោះមានសិទ្ធិនិងផលប្រយោជន៍តាមកថាខណ្ឌទីពីរទេ។

**មាត្រា ៩០** ក្នុងអាណត្តិចាប់ផ្តើម អោយតែងតាំងលេខាធិការ កសថផ. តាមព្រះរាជបញ្ញត្តិនេះ ក្នុងអំឡុងពេលកៅសិបថ្ងៃចាប់ពីថ្ងៃដែលមានការតែងតាំង កសថផ. តាមព្រះរាជបញ្ញត្តិនេះ។

ក្នុងអំឡុងពេលដែលមិនទាន់មានលេខាធិការ កសថឆ. តាមព្រះរាជបញ្ញត្តិនេះ អោយលេខាធិការគណៈកម្មការកិច្ចការទូរគមនាគមន៍ជាតិតាមព្រះរាជបញ្ញត្តិអង្គការរៀបចំរលកអាកាសនិងគ្រប់គ្រងកិច្ចការវិទ្យុសំលេង វិទ្យុទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ ព.ស.២៥៤៣ ដែលកាន់តំណែងនៅមុនថ្ងៃដែលព្រះរាជបញ្ញត្តិនេះចូលជាធរមានកាន់តំណែងជាបណ្តោះអាសន្ន។

**មាត្រា ៩១** អោយផ្ទេរប្រាក់និងទ្រព្យរបស់មូលនិធិអភិវឌ្ឍន៍កិច្ចការផ្សាយសំលេងនិងកិច្ចការទូរទស្សន៍ដើម្បីសាធារណៈប្រយោជន៍ និងមូលនិធិអភិវឌ្ឍន៍កិច្ចការទូរគមនាគមន៍ដើម្បីសាធារណៈប្រយោជន៍តាមព្រះរាជបញ្ញត្តិអង្គការរៀបចំរលកអាកាសនិងគ្រប់គ្រងកិច្ចការវិទ្យុសំលេង វិទ្យុទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ ព.ស.២៥៤៣ ដែលមាននៅក្នុងថ្ងៃដែលព្រះរាជបញ្ញត្តិនេះចូលជាធរមាន អោយទៅជារបស់មូលនិធិតាមព្រះរាជបញ្ញត្តិនេះ។

**មាត្រា ៩២** អោយបណ្តកិច្ចការ ទ្រព្យ សិទ្ធិ ទូនាទី របស់នាយកដ្ឋានទំនាក់ទំនងសាធារណៈ ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ក្នុងផ្នែកដែលទាក់ទងនឹងកងការងារគណៈកម្មការកិច្ចការវិទ្យុសំលេងនិងវិទ្យុទូរទស្សន៍ជាតិ នាយកដ្ឋានទំនាក់ទំនងសាធារណៈ ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ដែលមាននៅក្នុងថ្ងៃដែលព្រះរាជបញ្ញត្តិនេះចូលជាធរមាន ទៅជារបស់ការិយាល័យ កសថឆ. លើកលេងតែប្រាក់ថវិកាជំពូកប្រាក់ខែនិងប្រាក់ថ្លៃឈ្នួលដែលមានអ្នកគ្រប់គ្រងអោយផ្ទេរទៅជារបស់នាយកដ្ឋានទំនាក់ទំនងសាធារណៈ ខុទ្ទកាល័យនាយករដ្ឋមន្ត្រី។

**មាត្រា ៩៣** មន្ត្រីរាជការនិងបុគ្គលិករបស់កងការងាយគណៈកម្មការកិច្ចការវិទ្យុសំលេងនិងវិទ្យុទូរទស្សន៍ជាតិ នាយកដ្ឋានទំនាក់ទំនងសាធារណៈ ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ដែលកាន់តំណែងនៅមុនថ្ងៃដែលព្រះរាជបញ្ញត្តិនេះចូលជាធរមាន។ បើពេញចិត្តផ្ទេរទៅជាបុគ្គលិករបស់ការិយាល័យ កសថឆ. នៅពេលដែលសម្តែងចេតនាជាលាយលក្ខណ៍អក្សរចំពោះមេបញ្ជាការក្នុងកៅសិបថ្ងៃចាប់ពីថ្ងៃដែលព្រះរាជបញ្ញត្តិនេះចូលជាធរមាន។ អោយ កសថឆ. តែងតាំងមន្ត្រីរាជការឬបុគ្គលិកនោះជាមន្ត្រីរាជការឬបុគ្គលិករបស់ការិយាល័យ កសថឆ. តាមលក្ខណ្ឌដែល កសថឆ. បានកំណត់។ ប៉ុន្តែនឹងកំណត់អោយទទួលប្រាក់ខែឬថ្លៃឈ្នួលតិចជាងមុនមិនបានឡើយ។ សម្រាប់អ្នកដែលមិនបង្ហាញបំណងចេតនាក្នុងរយៈពេលនោះ អោយត្រឡប់ទៅបំពេញទូនាទីនៅនាយកដ្ឋានទំនាក់ទំនងសាធារណៈ ខុទ្ទកាល័យនាយករដ្ឋមន្ត្រី។

នៅអំឡុងពេលដែលមិនទាន់មាន កសថឆ. តាមព្រះរាជបញ្ញត្តិនេះ អោយអំណាចរបស់ កសថឆ. តាមកថាខណ្ឌទីមួយជាអំណាចរបស់គណៈកម្មការកិច្ចការទូរគមនាគមន៍ជាតិដែលបានតែងតាំងតាមព្រះរាជ

បញ្ញត្តិអង្គការរៀបចំរលកអាកាសនិងគ្រប់គ្រងកិច្ចការវិទ្យុសំលេង វិទ្យុទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ ព.ស. ២៥៤៣។

**មាត្រា ៩៤** ការតែងតាំងមន្ត្រីរាជការតាមមាត្រា ៩៣ អោយចាត់ទុកថាជាការអោយចេញពីរាជការ។ ពីព្រោះជាការបញ្ឈប់ឬលុបមុខតំណែងតាមច្បាប់ស្តីពីសោធននិវត្តន៍មន្ត្រីរាជការ ឬច្បាប់ស្តីពីមូលនិធិសោធននិវត្តន៍មន្ត្រីរាជការ។

ការតែងតាំងបុគ្គលិកតាមមាត្រា ៩៣ អោយចាត់ទុកថាជាការចេញពីការងារ។ ពីព្រោះរាជការលុបមុខតំណែងឬបញ្ឈប់ការជួលដោយមិនមានកំហុស ហើយអោយបានទទួលប្រាក់សោធននិវត្តន៍តាមរបៀបក្រសួងហិរញ្ញវត្ថុស្តីពីប្រាក់សោធននិវត្តន៍បុគ្គលិក។

**មាត្រា ៩៥** អោយបណ្តូរបៀប បទដ្ឋាន ប្រកាស ឬបទបញ្ជាដែលចេញតាមព្រះរាជបញ្ញត្តិអង្គការរៀបចំរលកអាកាសនិងគ្រប់គ្រងកិច្ចការវិទ្យុសំលេង វិទ្យុទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ ព.ស.២៥៤៣ ដែលស្របច្បាប់ហើយនៅជាធរមានក្នុងថ្ងៃដែលព្រះរាជបញ្ញត្តិនេះចូលជាធរមាន អោយនៅជាធរមានបើមិនជំទាស់នឹងព្រះរាជបញ្ញត្តិនេះ លុះត្រាដល់មានរបៀប បទដ្ឋាន ប្រកាស ឬបទបញ្ជាដែលចេញតាមព្រះរាជបញ្ញត្តិនេះ

អ្នកទទួលព្រះប្រមរាជរាជឱង្ការ

អភិសិទ្ធិ វេតឆាឈីវៈ

នាយករដ្ឋមន្ត្រី

កត់សំគាល់: មូលហេតុក្នុងការប្រកាសអោយប្រើព្រះរាជបញ្ញត្តិនេះ គឺ តាមមាត្រា ៤៧ របស់រដ្ឋធម្មនុញ្ញនៃរាជាណាចក្រថៃ បានបញ្ញត្តិអោយមានអង្គការរដ្ឋដែល ជា អង្គការសេរីមួយ ដែល មានទូនាទីដំណើរការរៀបចំរលកអាកាសនិងគ្រប់គ្រងការប្រកបអាជីវកម្មកិច្ចការវិទ្យុសំលេង វិទ្យុទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍។ ដោយតាមច្បាប់បានបញ្ញត្តិនិងតាមមាត្រា ៣០៥ (១) បញ្ញត្តិអោយច្បាប់រៀបចំអង្គការដែលបានបញ្ញត្តិឡើងត្រូវមានសារៈសំខាន់ដោយមានគណៈកម្មការឯកទេសជាអង្គភាពកូនក្នុងអង្គការនោះដោយចែកគ្នាដោយឡែក។ មានទូនាទីគ្រប់គ្រងការប្រកបអាជីវកម្មកិច្ចការផ្សាយសំលេងនិងវិទ្យុទូរទស្សន៍ និងគ្រប់គ្រងការប្រកបអាជីវកម្មកិច្ចការទូរគមនាគមន៍ និងមានពត៌មានស្តីពីការគ្រប់គ្រងនិងការពារការដំណើរកិច្ចការ ការរៀបចំអោយមានមូលនិធិអភិវឌ្ឍន៍ធនធានទំនាក់ទំនងនិងជំរុញប្រជាជនអោយចូលរួមក្នុងការដំណើរការសារពត៌មានសាធារណៈ។ ជាមួយនឹងព្រះរាជបញ្ញត្តិអង្គការរៀបចំរលកអាកាសនិងគ្រប់គ្រងកិច្ចការវិទ្យុសំលេង វិទ្យុទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍ ព.ស.២៥៤៣ បានចូលជាធរមានមកយូរហើយ ប៉ុន្តែមិនសូវមានលទ្ធផលក្នុងការអនុវត្ត។បង្កអោយមានការរាំងស្ទះក្នុងការដំណើរការរួមទាំងមានបទបញ្ញត្តិដែលមិនស្របនឹងរដ្ឋធម្មនុញ្ញនៃរាជាណាចក្រថៃ។ ជាការគួរសមកំណត់អោយរៀបចំអង្គការរដ្ឋដែលជាអង្គការសេរីមួយអង្គការមានទូនាទីដំណើរការរៀបចំរលកអាកាសនិងគ្រប់គ្រងការប្រកបអាជីវកម្មកិច្ចការវិទ្យុសំលេង វិទ្យុទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍។ រួមទាំងកំណត់ក្របខណ្ឌការដំណើរការរបស់អង្គការនិងគ្រប់គ្រងការប្រកបអាជីវកម្មនោះ និងកែសម្រួលច្បាប់ស្តីពីអង្គការរៀបចំរលកអាកាសនិងគ្រប់គ្រងកិច្ចការវិទ្យុសំលេង វិទ្យុទូរទស្សន៍ និងកិច្ចការទូរគមនាគមន៍អោយបានកាន់តែល្អប្រសើរ។ ដើម្បីអោយស្របទៅតាមបទបញ្ញត្តិរបស់រដ្ឋធម្មនុញ្ញនៃរាជាណាចក្រថៃ ទើបចាំបាច់ត្រូវត្រាព្រះរាជបញ្ញត្តិនេះ។

This translated version is prepared with the sole purpose of facilitating the comprehension of foreign participants in the telecommunication rules and regulations and shall not in any event or by any reason be construed or interpreted as having effect in substitution for supplementary to the Thai version thereof. If its translation to other languages is in contrary to Thai version, the latter shall prevail.

Please note that the translation has not been subjected to an official review by the Office of the National Broadcasting and Telecommunications Commission. The Office of NBTC, accordingly, shall not undertake any responsibility for its accuracy, nor be held liable for any loss or damages arising from or in connection with its use.